Peace Corps
CAMBODIA

# របាយការណ៍ប្រចាំឆ្នាំ

# ២០២៥



## ទីភ្នាក់ងារ ភីស ខ័រ កម្ពុជា

ផ្ទះលេខ ៧អា ផ្លូវលេខ ២៥៦

រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ២៤៥៣

ទូរស័ព្ទលេខ៖ (៨៥៥) ២៣ ២២២ ៩០១

ទូរសារលេខ៖ (៨៥៥) ២៣ ២២២ ៩០៣

អ៊ីម៉ែល៖ KH-WebInfo@peacecorps.gov

**PC Facebook:** **PC Instagram:** **PC Website:**

## ខែធ្នូ ឆ្នាំ ២០២៤

ទីភ្នាក់ងារ ភីស ខ័រ គឺជាស្ថាប័នដែលមិនប្រកាន់និន្នាការនយោបាយ និងសាសនា របស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ដែលធ្វើការដើម្បីលើកកម្ពស់សន្តិភាព និងមិត្តភាព រវាងប្រជាជននៃប្រទេស និងវប្បធម៌ផ្សេងគ្នា។ អស់រយៈពេលជាង ប្រាំមួយទស្សវត្សរ៍កន្លងទៅនេះ ទីភ្នាក់ងារ ភីស ខ័រ បានផ្តល់ជំនួយបច្ចេកទេសដល់ប្រទេស ចំនួន ១៤១ តាមរយៈ ការអនុវត្តគម្រោង កសិកម្ម ការអភិវឌ្ឍសេដ្ឋកិច្ចសហគមន៍ ការអប់រំ បរិស្ថាន សុខភាព និងការអភិវឌ្ឍយុវជន។

# មាតិកានុក្រម


**សារពីនាយិកាប្រចាំប្រទេស** ២

**ទស្សនៈរួមជាសកលនៃទីភ្នាក់ងារ ភីស ខ័រ** ៣

**ទីភ្នាក់ងារ ភីស ខ័រ នៅកម្ពុជា** ៤

ការបង្រៀនភាសាអង់គ្លេស និងការបណ្តុះបណ្តាលគ្រូបង្រៀន ៤

សមិទ្ធផលកម្មវិធីអប់រំក្នុងឆ្នាំ ២០២៥ ៥

**ដំណើររឿងជោគជ័យនៃគម្រោងអប់រំ** ៦

អភិអំណាចរបស់ វិទូ ៦

សមាសភាគនៃជោគជ័យ ៧

ម៉ោងដែលខ្ញុំចូលចិត្តបំផុតនៃសប្តាហ៍! ៩

**កម្មវិធីគម្រោងអភិវឌ្ឍន៍ខ្នាតតូច និងសមិទ្ធផល** ១០

គម្រោងអភិវឌ្ឍន៍ខ្នាតតូចដែលដឹកនាំដោយសហគមន៍ ១០

- កែលម្អអនាម័យនៅក្នុងសហគមន៍ ១០
- គម្រោងកែលម្អសាលានិងការអប់រំ ១១
- បន្ទប់ពិសោធន៍កុំព្យូទ័រ ១២
- ទីលានបាល់បោះ ១៣

**ការត្រៀមរៀបចំជាមុនសម្រាប់ការបម្រើការងារ** ១៤

ការបណ្តុះបណ្តាលបឋម (PST) សម្រាប់ក្រុម K១៧ នៅខែសីហា ឆ្នាំ២០២៥ ១៤

ការបណ្តុះបណ្តាលក្នុងពេលបម្រើការងារ(IST) សម្រាប់ក្រុម K១៦ នៅខែមករា ឆ្នាំ ២០២៥ ១៦

ការបណ្តុះបណ្តាលស្តីពីការរៀបចំ និងគ្រប់គ្រងគម្រោង (PDM) សម្រាប់អ្នកស្ម័គ្រចិត្ត និងដៃគូពួកគេ ក្នុងខែមីនា ឆ្នាំ២០២៥ ១៧

ការបណ្តុះបណ្តាលពាក់កណ្តាលការបំពេញការងារ(MST)សម្រាប់ក្រុម K១៦ នៅក្នុងខែវិច្ឆិកា ឆ្នាំ ២០២៥ ១៨

សិក្ខាសាលាបញ្ចប់ការបម្រើការងារ (COS) សម្រាប់ក្រុម K១៥ ក្នុងខែកញ្ញា ឆ្នាំ ២០២៥ ១៨

វគ្គបណ្តុះបណ្តាលសម្រាប់សមាជិកសហគមន៍ ១៨

- ជំនួបជាមួយគ្រួសារម្ចាស់ផ្ទះ សម្រាប់ក្រុមអ្នកស្ម័គ្រចិត្តថ្មី ក្នុងខែកញ្ញា ឆ្នាំ២០២៥ ១៩
- ការបណ្តុះបណ្តាលគ្រូដៃគូកម្រិតបឋមសិក្សា ក្នុងខែកញ្ញា ឆ្នាំ២០២៥ ១៩
- សិក្ខាសាលាស្តីពី គណៈគ្រប់គ្រងសាលា និងគ្រូដៃគូ ខែកញ្ញា ឆ្នាំ២០២៥ ២០

**ដំណើររឿងជោគជ័យពីអ្នកស្ម័គ្រចិត្ត** ២១

ក្លឹបភាសាអង់គ្លេសក្នុងអំឡុងពេលវិសមកាល ២១

រៀនពីវិធីថ្មីៗក្នុងការថែទាំគ្រួសារនៅកម្ពុជា ២២



## សារពី

# នាយិកាប្រចាំប្រទេស

បេសកកម្មរបស់ទីភ្នាក់ងារ ភីស ខ័រ គឺ ***"សន្តិភាព និង មិត្តភាពពិភពលោក"*** យើងបំពេញបេសកកម្មរបស់យើង តាមរយៈការបម្រើសេវាកម្ម ជាអ្នកស្ម័គ្រចិត្ត។ អ្នកស្ម័គ្រចិត្ត របស់យើងរស់នៅនិងធ្វើការរយៈពេលពីរឆ្នាំនៅក្នុង សហគមន៍ ជាមួយគ្រួសារខ្មែរ ដើម្បីជ្រួតជ្រាប និងសម្របខ្លួនតាម វប្បធម៌ក្នុងមូលដ្ឋាន។ ប្រការនេះនឹង ជួយឱ្យពួកគេ បង្កើតបាននូវទំនាក់ទំនងប្រកបដោយ អត្ថន័យ មើលឃើញពីទស្សនៈថ្មីមួយ និងរួមចំណែកដល់ការអភិវឌ្ឍកម្ពុជា និងប្រើប្រាស់ជំនាញបច្ចេកទេសរបស់ពួកគេយ៉ាងសមស្របនៅក្នុង បរិស្ថាន និង វប្បធម៌ថ្មី។

អ្នកស្ម័គ្រចិត្ត បាននឹងកំពុងធ្វើការជាមួយគ្រូបង្រៀននៅទូទាំងប្រទេស ដើម្បីរួមចំណែកដល់ការអភិវឌ្ឍការអប់រំ ភាសាអង់គ្លេសនៅកម្ពុជា។ លើសពីនេះ ពួកគេបានធ្វើការជាមួយសហការី និង មិត្តភក្តិក្នុងស្រុក លើគម្រោងអភិវឌ្ឍន៍ សហគមន៍ ផ្សេងៗជាច្រើន ដូចជាការអភិវឌ្ឍសួនដំណាំសាលា ដែលជួយកែលម្អ អាហារូបត្ថម្ភរបស់កុមារនិងគ្រួសារ ឬការបង្កើតបណ្ណាល័យមួយ ដែលជាធនធានមួយសម្រាប់សាលារៀន និង សហគមន៍។

មិនថាពួកគេធ្វើការជាគ្រូបង្រៀន ឬជាមួយសហគមន៍លើគម្រោងអភិវឌ្ឍន៍មួយក្តី ក៏គោលដៅគឺជាការកសាងសមត្ថភាព ក្នុងមូលដ្ឋានដែរ។ តាមរយៈធ្វើការជាមួយអ្នកស្ម័គ្រចិត្ត សមាជិកសហគមន៍ អាចរៀនសូត្រដើម្បីកំណត់សមត្ថភាព ជាអ្នកដឹកនាំរៀនរកធនធាន និងរៀនអនុវត្ត ការធ្វើការរួមគ្នា ឆ្ពោះទៅកាន់ គោលដៅអភិវឌ្ឍន៍ សហគមន៍ដែល បំពេញតាម សេចក្តីត្រូវការ និងកាលានុវត្តភាពនានាដែលបានកំណត់ជាអាទិភាពដោយសហគមន៍។ តួនាទីរបស់ អ្នកស្ម័គ្រចិត្ត គឺចូលរួមជាសមាជិកថ្មី មួយរូបនៃសហគមន៍ និងជួយសម្រួលកិច្ចដំណើរការនេះ។

នៅពេលធ្វើការ និងរស់នៅក្នុងសហគមន៍ អ្នកស្ម័គ្រចិត្តរបស់យើងក៏ចែករំលែកផងដែរនូវភាពខុសគ្នានៃវប្បធម៌ និងទំនៀមទម្លាប់ផ្សេងៗ របស់សហរដ្ឋអាមេរិក ដើម្បីជួយឱ្យប្រសើរឡើងនូវទំនាក់ទំនងរវាងប្រជាជននៃប្រទេស ទាំងពីរ។ អ្នកស្ម័គ្រចិត្តអាចចែករំលែកអំពីវប្បធម៌ និងប្រពៃណី ដ៏សម្បូណ៌បែបនៃប្រទេសកម្ពុជាដែលពួកគេបានរៀន ទៅកាន់គ្រួសារ និងមិត្តភក្តិនៅសហរដ្ឋអាមេរិក។ មិត្តភាពដែលបានបង្កើតឡើងក្នុងអំឡុងពេលពីរឆ្នាំនៃការរស់នៅ និងធ្វើការនៅក្នុងសហគមន៍នៅកម្ពុជាតាមរយៈការចែករំលែកគ្នានេះ អាចស្ថិតស្ថេរពេញមួយជីវិត និងជាកម្លាំងជំរុញ នៅពីក្រោយបេសកកម្មយើងក្នុងការកសាង សន្តិភាព និង មិត្តភាព ពិភពលោក។

យើងបន្តថ្លែងអំណរគុណចំពោះភាគីម្ចាស់ផ្ទះ ពោលគឺរាជរដ្ឋាភិបាលកម្ពុជា ដែលធ្វើឱ្យ កិច្ចសហការនេះអាចដំណើរការបានតាមរយៈការអញ្ជើញទីភ្នាក់ងារ ភីស ខ័រ ឱ្យមកធ្វើការក្នុងភាពជាដៃគូ ដើម្បីបំពេញគម្រោងអភិវឌ្ឍន៍ដែលជា អាទិភាព របស់រាជរដ្ឋាភិបាលកម្ពុជានៅថ្នាក់ជាតិ ខេត្ត ស្រុក និងឃុំ។ របាយការណ៍ប្រចាំឆ្នាំនេះ ក៏ចូលរួម អបអរសាទរ ខួប ១៨ ឆ្នាំនៃកិច្ចសហការជាមួយមន្ត្រីសមភាគី ដៃគូអ្នកមានវិជ្ជាជីវៈកម្ពុជានៅក្នុងគ្រឹះស្ថាន អប់រំនានា និងការកសាង ទំនាក់ទំនងជាមួយគ្រួសារខ្មែរក្នុងកម្រិតសហគមន៍ និង ជាលក្ខណៈបុគ្គល។

ទិន្នន័យនិងដំណើររឿងដែលចែករំលែកនៅក្នុងរបាយការណ៍ ប្រចាំឆ្នាំ២០២៥ នេះតំណាងឱ្យស្មារតី នៃយុទ្ធសាស្ត្រ អភិវឌ្ឍន៍រវាងមនុស្ស និងមនុស្សរបស់ទីភ្នាក់ងារ ភីស ខ័រ ដែលអាចកើតឡើងបានតែនៅពេលដែលយើងរៀនសូត្រនិង រីកចម្រើនរួមគ្នា តែប៉ុណ្ណោះ។ យើងមានមោទកនភាពក្នុងការចែករំលែកសមិទ្ធផលសហការរបស់អ្នកស្ម័គ្រចិត្តរបស់យើងនិងសមភាគីកម្ពុជានៅក្នុងឆ្នាំ២០២៥តាមរយៈរបាយការណ៍ប្រចាំឆ្នាំនេះ។

# ទស្សនៈរួមជាសកលនៃទីភ្នាក់ងារ ភីស ខ័រ

ទីភ្នាក់ងារ ភីស ខ័រ បញ្ជូនជនជាតិអាមេរិក ប្រកបដោយចំណេះដឹងដែលជាតំណាងឱ្យសហរដ្ឋអាមេរិកទៅក្រៅប្រទេស ដើម្បីចូលរួមជួយដោះស្រាយតម្រូវការចាំបាច់បំផុតរបស់ប្រជាជននៅជុំវិញពិភពលោក។ អ្នកស្ម័គ្រចិត្ត ធ្វើការនៅតាមកម្រិតមូលដ្ឋានដើម្បីអភិវឌ្ឍដំណោះស្រាយប្រកបដោយនិរន្តរភាព ដែលដោះស្រាយបញ្ហាប្រឈមនានានៅក្នុងវិស័យកសិកម្ម ការអភិវឌ្ឍសេដ្ឋកិច្ចសហគមន៍ ការអប់រំ បរិស្ថាន សុខភាព និងការអភិវឌ្ឍយុវជន។ តាមរយៈសេវាកម្មរបស់ពួកគេ អ្នកស្ម័គ្រចិត្តទទួលបាននូវការយល់ដឹងពីវប្បធម៌ ដោយឡែកជាមួយនឹងការប្តេជ្ញាចិត្តក្នុងមួយជីវិតរបស់គេ ក្នុងការបម្រើការងារដែលអាចឱ្យពួកគេស្ថិតក្នុងតួនាទីមួយដែលនាំឱ្យពួកគេទទួលបានភាពជោគជ័យក្នុងសង្គម នាពេលបច្ចុប្បន្ន និងអនាគត។

ទីភ្នាក់ងារនេះ បានចាប់កំណើតតាំងពីឆ្នាំ ១៩៦០ នៅពេលដែលអតីតសមាជិកព្រឹទ្ធសភា លោក John F. Kennedy បានជំរុញឱ្យនិស្សិតនៅសកលវិទ្យាល័យមីឈីហ្គេន (University of Michigan) ទៅរស់នៅ និងធ្វើការនៅទីកន្លែងឆ្ងាយដាច់ស្រយាលបំផុតនៅលើពិភពលោក។ លោកបានជំរុញយុវជនអាមេរិកាំង និងប្រទេសជាតិទាំងមូល ដោយឈានដល់ការបង្កើតទីភ្នាក់ងារ ភីស ខ័រនេះឡើង។ នៅក្នុងពិភពលោកមួយដែលប្រែប្រួលមិនឈប់ឈរ ទីភ្នាក់ងារនេះបានក្លាយជាទីភ្នាក់ងារឆ្នើម និងប្រកបដោយថាមភាព និងដើរឆ្ពោះទៅមុខ ក្នុងវិស័យសេវាកម្មអន្តរជាតិដោយសារគំនិតច្នៃប្រឌិតថ្មី និងមេត្តាធម៌របស់ខ្លួន ប៉ុន្តែ បេសកកម្មដំបូងរបស់ទីភ្នាក់ងារគឺស្ថិតនៅដដែល។

ទីភ្នាក់ងារ ភីស ខ័រ នៅតែមានការតាំងចិត្តខ្ពស់ចំពោះ ការលើកកម្ពស់សន្តិភាព និងការកសាងមិត្តភាពពិភពលោក។ ចាប់តាំងពីការចាប់កំណើតនៅឆ្នាំ ១៩៦១មក អ្នកស្ម័គចិត្រ ភីស ខ័រ ច្រើនជាង ២៤០,០០០នាក់បានបម្រើការងារ នៅក្នុង ១៤៤ ប្រទេស និងធ្វើការសហការកសាងទំនាក់ទំនង និងផ្លាស់ប្តូរវប្បធម៌ ចំណេះដឹងជាមួយដៃគូការងារ និងសមាជិកសហគមន៍។ ថ្ងៃនេះអ្នកស្ម័គ្រចិត្ត ភីស ខ័រ តាំងចិត្ត ប្តេជ្ញាចិត្ត និងប្រើប្រាស់ជំនាញរបស់គេ ដើម្បីគាំទ្រគម្រោងអភិវឌ្ឍនដែលដឹកនាំដោយសហគមន៍ និងការផ្លាស់ប្តូរអន្តរវប្បធម៌។ ការងាររបស់ ភីស ខ័រ បើកឱកាសពិភពលោកដែលអភិវឌ្ឍន៍ជំនាញ បទពិសោធន៍ និងភាពរីករាយចំពោះអ្នកស្ម័គ្រចិត្ត។

## គោលដៅទាំងបីរបស់យើង

1. ផ្តល់អ្នកស្ម័គ្រចិត្ត ទាំងបុរស និង ស្ត្រី ដែលបានទទួលការបណ្តុះបណ្តាល ទៅចូលរួម ជួយប្រជាជន នៅក្នុងបណ្តាប្រទេសដែលចាប់អារម្មណ៍ លើទីភ្នាក់ងារ ភីស ខ័រ ។
2. ជួយអ្នកស្ម័គ្រចិត្តអាមេរិកាំងអោយមានការយល់ដឹងកានតែប្រសើរឡើង អំពីប្រជាជនដែលពួកគេធ្វើការ ជាមួយ ។
3. ជួយអោយប្រជាជាតិដទៃមានការយល់ដឹងកាន់តែប្រសើរឡើង អំពីជនជាតិអាមេរិកាំង។




### ភីស ខ័រ បច្ចុប្បន្ន

**៦០+** ចំនួនប្រទេសដែលមានអ្នកស្ម័គ្រចិត្ត

**៣,០០០+** អ្នកស្ម័គ្រចិត្ត និងសិក្ខាកាមភីស ខ័រ

**៥៦.២៩%** ស្ត្រី

**៤៣.៧១%** បុរស

**២៨** អាយុជាមធ្យមនៃអ្នកស្ម័គ្រចិត្ត

**៧.១៦%** អ្នកស្ម័គ្រចិត្តដែលមានអាយុលើសពី ៥០ឆ្នាំ

# ទីភ្នាក់ងារ ភីស ខ័រ នៅកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជាបានអញ្ជើញទីភ្នាក់ងារ ភីស ខ័រ ជាលើកដំបូងឱ្យបើកកម្មវិធីនៅកម្ពុជានៅចុងឆ្នាំ ១៩៩២ កិច្ចព្រមព្រៀងរវាងប្រទេសទាំងពីរត្រូវបានចុះហត្ថលេខានៅឆ្នាំ ១៩៩៤។ ដោយសារស្ថានការណ៍នោះ មិនមានស្ថេរភាពគ្រប់គ្រាន់សម្រាប់អ្នកស្ម័គ្រចិត្តចូលមកបម្រើការងារនៅប្រទេសកម្ពុជា។ នៅឆ្នាំ ២០០៤ ការពិភាក្សាអំពីការបង្កើតកម្មវិធីឡើងវិញត្រូវបានបន្ត ហើយទីភ្នាក់ងារ ភីស ខ័រ កម្ពុជា បានទទួលស្វាគមន៍ ក្រុមអ្នកស្ម័គ្រចិត្តដំបូងនៅឆ្នាំ ២០០៧។

ចាប់តាំងពីកម្មវិធីបានបើកដំណើរការនៅឆ្នាំ ២០០៧ មក មានអ្នកស្ម័គ្រចិត្តសរុបចំនួន ៧៧៦ នាក់ ដែលបាន បម្រើការងារនៅកម្ពុជា។ ក្នុងនោះ មាន ៥៦៣ នាក់ជាគ្រូបង្រៀនភាសាអង់គ្លេស និង ២១៣ នាក់ជាអ្នកស្ម័គ្រចិត្ត អប់រំសុខភាពសហគមន៍។ បច្ចុប្បន្ននេះ ទីភ្នាក់ងារ ភីស ខ័រ មានគម្រោងបច្ចេកទេសតែមួយ នៅកម្ពុជា គឺ ការបង្រៀនភាសាអង់គ្លេស និងការបណ្តុះបណ្តាលគ្រូបង្រៀន។

អ្នកស្ម័គ្រចិត្តរស់នៅជាមួយគ្រួសារខ្មែរ រយៈពេលពីរឆ្នាំ ដោយមានកម្រិតជីវភាពស្រដៀងនឹងប្រជាពលរដ្ឋកម្ពុជា នៅក្នុងសហគមន៍របស់ពួកគេ។ ពួកគេធ្វើការរួមគ្នាជាមួយប្រជាជនកម្ពុជា ដើម្បីជួយអនុវត្តការងារដែលមានអត្ថន័យ សម្រាប់អនាគតល្អប្រសើររបស់សហគមន៍ និងសម្រាប់ប្រទេសកម្ពុជា។




**៦១** នាក់ ចំនួនអ្នកស្ម័គ្រចិត្តបច្ចុប្បន្ន:

**៣១** នាក់ ស្រី

**៣០** នាក់ បុរស

**១** នាក់ប្រធានក្រុមអ្នកស្ម័គ្រចិត្តភីស ខ័រ ( PCVL )

**១** សាលាគរុកោសល្យខេត្ត

**៣១** វិទ្យាល័យ

**៦** អនុវិទ្យាល័យ

**២២** សាលាបឋមសិក្សា

## ការបង្រៀនភាសាអង់គ្លេស និងការបណ្តុះបណ្តាលគ្រូបង្រៀន

គម្រោងបង្រៀនភាសាអង់គ្លេស និងបណ្តុះបណ្តាលគ្រូ (ETTT) បានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡានៅកម្ពុជាតាំងពីឆ្នាំ ២០០៧។ គម្រោងនេះបានធ្វើការដើម្បីអភិវឌ្ឍភាសាអង់គ្លេសរបស់សិស្ស គ្រូ និងសមាជិកសហគមន៍កម្ពុជា ដើម្បីជួយពួកគេឱ្យមានលទ្ធភាពទទួលបានឱកាសផ្ទាល់ខ្លួន ឱកាសវិជ្ជាជីវៈ និងឱកាសសិក្សា។

អ្នកស្ម័គ្រចិត្តបង្រៀននៅតាម សាលាបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ និង មជ្ឈមណ្ឌលគរុកោសល្យ។ អ្នកស្ម័គ្រចិត្តសហការបង្រៀនជាមួយគ្រូជាជនជាតិខ្មែរ តាមសំណើរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ការអនុវត្តបែបនេះមិនត្រឹមតែផ្តល់អត្ថប្រយោជន៍ដល់សិស្សប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពង្រឹងសមត្ថភាពភាសារបស់គ្រូបង្រៀនកម្ពុជា និងកសាងជំនាញ បច្ចេកទេសគ្រប់គ្រងថ្នាក់រៀនរបស់ពួកគេទៀតផង។ តាមរយៈការបង្រៀនជាមួយគ្រូជនជាតិខ្មែរ អ្នកស្ម័គ្រចិត្តចែករំលែកការអនុវត្តការបង្រៀនប្រកបដោយភាពច្នៃប្រឌិត ជួយរៀបចំកិច្ចតែងការបង្រៀន និងបង្រៀនមេរៀន ជួយកសាងជំនាញភាសាអង់គ្លេសសម្រាប់ទំនាក់ទំនង និងណែនាំបច្ចេកទេសគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព។ អ្នកស្ម័គ្រចិត្ត ក៏បង្កើត និងលើកកម្ពស់ផងដែរនូវធនធានបង្រៀននិងរៀនសម្រាប់ថ្នាក់រៀន រួមមានល្បែងសិក្សា និងណែនាំអំពីបច្ចេកវិទ្យាថ្មីៗផងដែរ។

ចាប់តាំងពីគម្រោងនេះបានចាប់ផ្តើមដំណើរការក្នុងឆ្នាំ ២០០៧ រហូតមកដល់ឆ្នាំ២០២៤ ពួកយើងទទួលបានអ្នកស្ម័គ្រចិត្តចំនួន ៧៥១ នាក់បម្រើការងារនៅកម្ពុជា។ ដែលក្នុងនោះមានអ្នកស្ម័គ្រចិត្តចំនួន ២១៣នាក់ បានធ្វើការងារលើគម្រោង អប់រំសុខភាពក្នុងសហគមន៍ និងអ្នកស្ម័គ្រចិត្តចំនួន ៥៣៨នាក់ ធ្វើការងារលើគម្រោង អប់រំភាសាអង់គ្លេសនៅតាមសាលារៀនក្នុងសហគមន៍។

## គោលដៅគម្រោង

សិស្សានុសិស្សកម្ពុជាទទួលបានជំនាញទំនាក់ទំនងជាភាសាអង់គ្លេស និងបំណិនជីវិតដែលចាំបាច់ដើម្បីមានលទ្ធភាពទទួលបានឱកាសសិក្សានិងឱកាសវិជ្ជាជីវៈ។

## គោលបំណងនៃគម្រោង

១. គ្រូបង្រៀន គ្រូឧទ្ទេស និងគរុនិស្សិត

– បង្កើនសមត្ថភាពគ្រូបង្រៀន គ្រូឧទ្ទេស និងគរុនិស្សិតដើម្បីប្រើជំនាញបង្រៀនភាសាអង់គ្លេសទូទៅឱ្យកាន់តែមានប្រសិទ្ធភាព។

– បង្កើនជំនាញភាសាអង់គ្លេសរបស់គ្រូភាសាអង់គ្លេស គ្រូឧទ្ទេស និងគរុនិស្សិត។

– បង្កើនសមត្ថភាពគ្រូបង្រៀន គ្រូឧទ្ទេស និងគរុនិស្សិតក្នុងការអនុវត្តគុណភាពនៃការចូលរួមរវាងស្ត្រី និងបុរស នៅក្នុងថ្នាក់រៀន។

២. សិស្ស

– បង្កើនសមិទ្ធផលរបស់សិស្សទៅលើភាសាអង់គ្លេស។

– បង្កើនបំណិនជីវិតរបស់សិស្ស។

៣. បរិយាកាសសិក្សា

កែលម្អបរិយាកាសសិក្សាសាលាតាមរយៈការកែលម្អសាលារៀន ការបង្កើនការចូលរួមរបស់សហគមន៍ និងការអភិវឌ្ឍធនធានសិក្សា។

## សមិទ្ធផលកម្មវិធីអប់រំក្នុងឆ្នាំ ២០២៥

### បង្កើនសមត្ថភាពគ្រូបង្រៀនក្នុងការប្រើជំនាញភាសាអង់គ្លេស និងជំនាញបង្រៀនទូទៅ

| | |
|---|---|
| **២៦៧** នាក់ | ចំនួនគ្រូដែលចូលរួមក្នុងការធ្វើផែនការ និងបង្រៀនភាសាអង់គ្លេសរួមគ្នា |
| **៩៣%** | ភាគរយនៃគ្រូបង្រៀនដែលបង្ហាញនូវចំនួនអប្បបរមានៃការអនុវត្តការបង្រៀនដែលត្រូវបានទទួលស្គាល់លើជំនាញបង្រៀនទូទៅ និងជំនាញបង្រៀនភាសាអង់គ្លេស |

### បង្កើនសមិទ្ធផលរបស់សិស្សលើជំនាញភាសាអង់គ្លេស និងបំណិនជីវិត

| | |
|---|---|
| **៦៩៨** | ចំនួនថ្នាក់ដែលអ្នកស្ម័គ្រចិត្តបង្រៀន |
| **២៤,៨១១** នាក់ (នារីៈ ១៣,២៣៦នាក់) | ចំនួនសិស្សដែលត្រូវបានបង្រៀនភាសាអង់គ្លេសនៅក្នុងសាលា |
| **៦២៦** នាក់ | ចំនួនសិស្សដែលចូលរួមក្លឹបភាសាអង់គ្លេសក្រៅកម្មវិធីសិក្សា វគ្គបង្ហាត់បង្រៀន និង/ឬសិក្ខាសាលា |
| **៨៣%** | ភាគរយសិស្សដែលបង្ហាញពីសមិទ្ធផលក្នុងវគ្គសិក្សាភាសាអង់គ្លេស |

### បង្កើនសមត្ថភាពរបស់សមាជិកសហគមន៍ដើម្បីគាំទ្រដល់ការចូលរៀនរបស់សិស្សានុសិស្ស តាមរយៈការកែលម្អបរិយាកាសសិក្សានៅសាលា

| | |
|---|---|
| **៧១០** នាក់ | ចំនួនសមាជិកសហគមន៍ដែលចូលរួមក្នុងគម្រោងកែលម្អបរិក្ខារសាលារៀន |
| **១០០%** | ភាគរយសមាជិកសហគមន៍ដែលរាយការណ៍ពីសកម្មភាពចូលរួមការងារសាលាដែលរៀបចំដោយអ្នកស្ម័គ្រចិត្ត បានបង្កើនសមត្ថភាពរបស់ពួកគេក្នុងការគាំទ្រដល់ការចូលរៀនរបស់សិស្ស |

# ដំណើររឿងជោគជ័យនៃគម្រោងអប់រំ

## អភិអំណាចរបស់ វិទូ ពីអ្នកស្ម័គ្រចិត្ត ភីស ខ័រ Jacob Crop នៅខេត្តស្ទឹងត្រែង




នៅក្នុងបន្ទប់រៀនថ្នាក់ទី៤ ខ្ញុំមានសិស្សម្នាក់ឈ្មោះ វិទូ។ គាត់គឺជាក្មេងម្នាក់ដែលគួរឱ្យចូលចិត្តបំផុតដែលខ្ញុំបានជួប ហើយដោយមិននិយាយបំផ្លើសគាត់គឺជាមនុស្សម្នាក់ក្នុងចំណោមមនុស្សគួរឱ្យចាប់អារម្មណ៍បំផុតដែល ខ្ញុំធ្លាប់ជួប។ ចំណុចមួយអំពី វិទូ គឺថាគាត់អាចនិយាយមិនចេះឈប់។ មិនថាអ្នកចូលរួមជាមួយគាត់ ឬព្យាយាមមិនឱ្យគាត់និយាយទេ គាត់តែងតែរកឃើញវិធីមួយដើម្បីបន្តការសន្ទនា។ ខ្ញុំមានអារម្មណ៍ថាដូចជាអភិអំណាចមួយ។ ថ្វីបើខ្ញុំធ្លាប់ជួបមនុស្សដែលនិយាយច្រើនពីមុនមកក្តី ក៏គ្មាននរណាម្នាក់អាចប្រៀបដូចជាមួយ វិទូ បានទេ ទាក់ទងនឹងការយល់ដឹង ថាមពល និងការចង់ដឹង។

អ្វីដែលធ្វើឱ្យគាត់ខុសប្លែកពីគេ គឺមិនមែនគ្រាន់តែការនិយាយរបស់គាត់ប៉ុណ្ណោះទេ ប៉ុន្តែជាខ្លឹមសារសំដីរបស់គាត់។ ភាសាអង់គ្លេសរបស់គាត់ គឺអស្ចារ្យសម្រាប់ក្មេងដែលមានអាយុស្របាលគាត់ ហើយគំនិតរបស់គាត់ច្រើនតែមានលក្ខណៈស៊ីជម្រៅ និងចាស់ទុំ។ វាអាចជាបញ្ហាប្រឈមមួយនៅក្នុងថ្នាក់រៀន ប៉ុន្តែ នៅពេលដែលអ្នកផ្តល់ឱកាសឱ្យគាត់និយាយ គាត់ច្រើនតែមានអ្វីដែលមានអត្ថន័យដើម្បីចែករំលែក។ ទោះជាយ៉ាងនេះក្តី ក៏ វិទូ មិនសូវចូលរួមច្រើនទេនៅក្នុងថ្នាក់រៀនតាមន័យប្រពៃណី។ នៅពេលដែលគាត់ចូលរួម ជាធម្មតា គឺដើម្បីនិយាយលេងកំប្លែង ឬសួរខ្ញុំនូវសំណួរមិនពាក់ព័ន្ធ ពីព្រោះគាត់យល់មេរៀនរួចទៅហើយ។ ប្រការនេះ ពិតជាធ្វើឱ្យខ្ញុំប្រយ័ត្នប្រយែងក្នុងអំឡុងពេលបង្រៀនថ្នាក់ទី ៤យ ហើយខ្ញុំតែងតែព្យាយាមស្វែងរកតុល្យភាពរវាងការរក្សារចនាសម្ព័ន្ធ និងការកោតសរសើរចំពោះថាមពលដែលគាត់នាំមក។

ពេលមួយដែលលេចធ្លោ បានកើតឡើងក្នុងអំឡុងពេលជួបជាមួយនាយកសហគមន៍របស់ខ្ញុំ និងគ្រូបង្រៀនផ្សេងទៀតមួយចំនួន។ យើងកំពុងធ្វើការលើថវិកាបឋមសម្រាប់គម្រោងជំនួយហិរញ្ញប្បទានមួយសម្រាប់សាងសង់សួនកុមារមួយ។ដូចសព្វមួយដងវិទូបានចូលមកដើម្បីនិយាយ។ ដំបូងឡើយ យើងបានប្រាប់គាត់យ៉ាងថ្នមៗឱ្យគាត់ចាកចេញ ប៉ុន្តែ គាត់បានដឹងយ៉ាងលឿនអំពីអ្វីដែលយើងកំពុងពិភាក្សា ហើយបានចាប់ផ្តើមចែករំលែកគំនិតរបស់គាត់។ គួរឱ្យភ្ញាក់ផ្អើល គាត់មានយោបល់ដ៏ស៊ីជម្រៅអំពីអ្វីដែលសិស្សចង់បាន សម្ភារៈអ្វីខ្លះដែលមាននៅក្នុងសហគមន៍ និងរបៀបដែលការរចនាអាចរៀបចំបានកាន់តែប្រសើរស្របទៅតាមតម្រូវការរបស់កុមារ។ គាត់បានក្លាយជាធនធានពិតប្រាកដមួយនៅពេលនោះ ហើយខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះការចូលរួមដ៏វាងវៃ និងមានលក្ខណៈចាស់ទុំរបស់គាត់។

ខ្ញុំពិតជាមានមោទនភាពយ៉ាងខ្លាំងចំពោះវិទូ និងសិស្សដទៃទៀតនៅសាលា។ ពួកគេមានភាពឆ្លាតវៃ មានការយល់ដឹង និងពោរពេញដោយសក្តានុពល។ ខ្ញុំមានអារម្មណ៍ថាខ្ញុំមានសំណាងដែលបានក្លាយជាផ្នែកមួយនៃការសិក្សា និងជីវិតរបស់ពួកគេហើយពួកគេបានជំរុញទឹកចិត្តខ្ញុំឱ្យក្លាយជាគ្រូបង្រៀនកាន់តែល្អមួយរូប និងជាគំរូសម្រាប់អ្នកដទៃ។














## សមាសភាគនៃជោគជ័យ ពីអ្នកស្ម័គ្រចិត្ត ភីស ខ័រ Uyen Tran នៅខេត្តពោធិ៍សាត់

នៅពេលដែលខ្ញុំនិងគ្រូដៃគូរបស់ខ្ញុំកំពុងរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ការប្រឡងសិស្សថ្នាក់ចុងក្រោយដើម្បីត្រៀមប្រឡងថ្នាក់ជាតិ យើងបានរកឃើញថាវាពិបាក ប៉ុន្តែអាចធ្វើបាន ដោយសារការផ្លាស់ប្តូរជាវិជ្ជមាននៃផ្នត់គំនិត និងអាកប្បកិរិយារបស់សិស្សានុសិស្ស។ ពេលវេលាដ៏មានមោទនភាពនេះ បានជំរុញឱ្យយើងបន្តការងារដ៏លំបាកនេះដោយការប្តេជ្ញាចិត្ត ទោះបីជាមានឧបសគ្គជាច្រើនដែលរារាំងយើងក្នុងនាមជាគ្រូបង្រៀនក៏ដោយ។ ការខិតខំប្រឹងប្រែង សន្ទុះដូច ដែលយើងរំពឹងទុក។

កាលពីខែវិច្ឆិកាកន្លងមកនិន្នាការនិងឥរិយាបថដ៏គួរឱ្យចាប់អារម្មណ៍របស់សិស្សបាននាំឱ្យមានការពិភាក្សាមួយជាមួយគ្រូបង្រៀនខ្មែរ។ សិស្សភាគច្រើន មានភាពខ្ជាស់អៀនខ្លាំង មិនចង់ចូលរួមក្នុងសកម្មភាពថ្នាក់រៀនជាច្រើនសប្តាហ៍មកហើយ ឬមានអាកប្បកិរិយារំខាន។ សិស្សមានភាពស្ទាក់ស្ទើរក្នុងការបញ្ចេញមតិផ្ទាល់ខ្លួន ឬបុគ្គលិកលក្ខណៈរបស់ពួកគេក្នុងអំឡុងពេលធ្វើសកម្មភាពចាប់ផ្តើមរបស់យើង។ ពួកគេផ្តល់ចម្លើយដូចគ្នាចំពោះសំណួររបស់យើង ទោះបីជាយើងបានបង្វែរសំណួរជាភាសាខ្មែរដើម្បីលើកទឹកចិត្តឱ្យមានចម្លើយខុសគ្នាក៏ដោយ។

មិនយូរប៉ុន្មាន ខ្ញុំបានសង្កេតឃើញថា បរិស្ថានសិក្សាពិតជាមានលក្ខណៈជាគ្រូមជ្ឈមណ្ឌល។ គ្រូជាអ្នកនិយាយ ហើយសិស្សជាអ្នករង់ចាំទទួលចម្លើយ និងចំណេះដឹង។ លើសពីនេះ ខ្ញុំបានសង្កេតឃើញថា សិស្សទាំងនោះស្ថិតនៅក្រោមសម្ពាធយ៉ាងខ្លាំងក្នុងការក្លាយជាមនុស្សដែលមានភាពល្អឥតខ្ចោះ ដូច្នេះ ខ្ញុំបានអង្គុយជាមួយគ្រូជនជាតិខ្មែរ ដែលនឹងក្លាយជាដៃគូរបស់ខ្ញុំនៅសាលា ដើម្បីដោះស្រាយនិន្នាការទាំងនេះ។ យើងបានកំណត់ថាតើពួកគេត្រូវការការគាំទ្រអ្វីខ្លះ និងតើការរំពឹងទុករបស់ពួកគេមានអ្វីខ្លះ។ ខ្ញុំមានគ្រូដៃគូបង្រៀនដែលមានបទពិសោធន៍ ដូច្នេះ យើងអាចផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតលើសិស្ស ក៏ដូចជាអនុញ្ញាតឱ្យគ្រូជនជាតិខ្មែរអនុវត្តអ្វីដែលពួកគេចង់កែលម្អក្នុងអភិក្រមរួមមួយ។

ជាបឋម ខ្ញុំបានចាប់ផ្តើមដាក់ឱ្យអនុវត្តនូវកិច្ចការ និងសកម្មភាព ដែលមានលក្ខណៈច្នៃប្រឌិតជាងមុន នៅពេលណាមេរៀនអនុញ្ញាត។ ការចូលរួមប្រភេទនេះ មានកម្រិតឧបសគ្គទាប រីករាយ និងបរិយាបន្ន។ វាជួយសិស្សគ្រប់កម្រិតក្នុងការរៀនអំពីការបញ្ចេញមតិផ្ទាល់ខ្លួន ការដោះស្រាយបញ្ហា និងការត្រិះរិះ។ អត្ថប្រយោជន៍ដ៏ធំមួយទៀត គឺទំនុកចិត្ត និងទំនាក់ទំនងល្អដែលយើងទទួលបាន។ ក្មេងៗដែលស្ងៀមស្ងាត់ ឬក្មេងៗខិល ក៏រីករាយនឹងសកម្មភាពទាំងនេះ ហើយពួកគេបង្ហាញខ្ញុំនូវស្នាដៃរបស់ពួកគេដោយភាពមោទនៈ។ ថ្នាក់រៀនមានសណ្តាប់ធ្នាប់ ហើយពួកគេផ្តោតលើសកម្មភាពជំនួសឱ្យការបង្កបញ្ហា។ យើងមិនចាំបាច់បង្ខំដំណើរការនោះទេ។ សិស្សរៀនបើកចិត្តចំពោះពួកយើង និងរៀនបញ្ចេញគំនិតរបស់ពួកគេបានកាន់តែប្រសើរ។ លើសពីនេះ ពួកគេបានចាប់ផ្តើមចែករំលែកជាមួយពួកយើង លើសពីនេះ ពួកគេបានចាប់ផ្តើមចែករំលែកអំពីខ្លួនឯងកាន់តែច្រើនដូចជា ចំណង់ចំណូលចិត្ត ទេពកោសល្យ ក្តីស្រមៃ បុគ្គលិកលក្ខណៈ និងសូម្បីតែសាវតារគ្រួសារ និងបញ្ហាប្រឈមផ្ទាល់ខ្លួនរបស់ពួកគេ។ ពួកគេក៏ពេញចិត្តចំពោះការសម្រាកផ្លូវចិត្ត នៅពេលធ្វើកិច្ចការសប្បាយៗទាំងនេះ ដើម្បីស្តារថាមពលឡើងវិញពីកាលវិភាគដ៏តានតឹងរបស់ពួកគេ។ ថ្នាក់រៀន កាន់តែងាយស្រួលគ្រប់គ្រង ហើយការចូលរួមពីសិស្សថ្មីៗ ក៏មានភាពប្រសើរឡើង។

ស្រដៀងគ្នានេះដែរ គ្រូបង្រៀនខ្មែរបានអនុញ្ញាតឱ្យខ្ញុំលេងសើចក្នុងពេលទំនេរនៅក្នុងថ្នាក់។ យើងអនុញ្ញាតឱ្យសិស្សប្រើគ្រាមភាសា និងនិន្នាការអ៊ីនធឺណិតដើម្បីពន្យល់វាក្យសព្ទនៃមេរៀន។ ពួកគេចូលចិត្ត ពីព្រោះវាមានលក្ខណៈជាក់ស្តែង និងរីករាយ ក្នុងការស្វែងយល់នៅខាងក្រៅសៀវភៅសិក្សា។ នៅពេលដែលពួកគេឃើញឃ្លាកំប្លែងៗ និងភាសាទាន់សម័យ ពួកគេបង្ហាញពីការយកចិត្តទុកដាក់កាន់តែប្រសើរឡើងចំពោះវាក្យសព្ទនៅក្នុងបរិបទវប្បធម៌មួយ ដូច្នេះ យើងព្យាយាមភ្ជាប់ទំនាក់ទំនងជាមួយមេរៀនរបស់ពួកគេដើម្បីឱ្យពួកគេអាចចងចាំព័ត៌មាននោះ។ ការចូលរួមក្នុងថ្នាក់រៀន បានកើនឡើងចាប់តាំងពីយើងចាប់ផ្តើមធ្វើឱ្យមេរៀនមានភាពសប្បាយរីករាយ និងប្រើភាសាដែលសិស្សមាន ចំណាប់អារម្មណ៍ក្នុងការរៀន។

ថ្វីបើយើងបានដាក់បញ្ចូលភាពសប្បាយរីករាយក្តី ក៏យើងបានធានាឱ្យប្រាកដថាវាគឺជាបរិស្ថានសិក្សាប្រកបដែលមានសុវត្ថិភាព។ សកម្មភាពតូចៗ ដូចជាការនិយាយអរគុណចំពោះការខិតខំ ឬការចូលរួមក្នុងម៉ោងរៀនមានប្រសិទ្ធភាពខ្ពស់។ ទន្ទឹមនឹងនេះ យើងយកចិត្តទុកដាក់កាន់តែច្រើនចំពោះការប្រើប្រាស់ភាសាវិជ្ជមាន ជំនួសពាក្យចោទប្រកាន់ ជាមួយនឹងការណែនាំលម្អិត ដើម្បីកំណត់ការរំពឹងទុក និងព្រំដែនច្បាស់លាស់សម្រាប់ឱ្យសិស្សអនុវត្តតាម។ សកម្មភាពងាយៗផ្សេងទៀត គឺត្រូវស្ថិតនៅក្នុងកម្រិតដូចគ្នាជាមួយសិស្សដើម្បីស្តាប់ពួកគេយ៉ាងពិតប្រាកដនៅពេលពួកគេព្យាយាមនិយាយអ្វីមួយឬយើងអនុញ្ញាតឱ្យពួកគេទទួលជំនួយពីមិត្តភក្តិផ្សេងទៀតដើម្បីរិះរកចម្លើយជាមួយគ្នា។ នេះគឺជាបច្ចេកទេសមួយដែលប្រើជាញឹកញាប់ជាមួយកុមារតូចៗ ប៉ុន្តែវានៅតែអាចអនុវត្តបានសម្រាប់សិស្សវិទ្យាល័យជាពិសេស សម្រាប់សិស្សដែលខ្មាស់អៀន និងមានភាពតានតឹងទាំងឡាយ។ សិស្សចង់ក្លាយជាផ្នែកមួយនៃថ្នាក់រៀន និងរហូតដល់បញ្ចេញអាកប្បកិរិយាដែលមានលក្ខណៈរំខាននៅពេលដែលពួកគេមានអារម្មណ៍ថាពាក្យសម្តីរបស់ពួកគេត្រូវបានគេមើលឃើញ និងទទួលស្គាល់នៅក្នុងថ្នាក់។ សិស្សទាំងនេះមានអារម្មណ៍ថាបានទទួលការគាំទ្រ និងមានអារម្មណ៍ជាផ្នែកមួយក្នុងការរៀនជាមួយមិត្តភក្តិរបស់ពួកគេ ដូច្នេះ សកម្មភាពលែងគួរឱ្យខ្លាច ឬគួរឱ្យធុញទ្រាន់ទៀតហើយ។ វាគឺជាជោគជ័យ នៅពេលដែលកុមារមានអារម្មណ៍សុវត្ថិភាព និងហ៊ានប្រថុយ។ ដូច្នេះ ខ្ញុំបានចាប់ផ្តើមឃើញមុខរបស់ពួកគេចូលរួមនៅក្នុងសកម្មភាព និងកិច្ចការក្នុងថ្នាក់រៀនកាន់តែច្រើនជាងមុន។ គ្រូដៃគូរបស់ខ្ញុំក៏បើកចិត្ត ក្នុងការកែលម្អបរិយាកាសរៀនសូត្រជាមួយខ្ញុំ ក្រោយពេលបានឃើញលទ្ធផលល្អ។ ពួកគេដឹងថាគ្រូអាចមានលក្ខណៈ តឹងរ៉ឹងផង និងចិត្តល្អផងក្នុងពេលតែមួយដោយប្រើប្រាស់វិធីសាស្ត្រផ្សេងៗដែលមានប្រសិទ្ធភាព ដើម្បីកាត់បន្ថយការប្រើការដាក់ពិន័យ និងការស្រែកឱ្យតិចជាងមុន។ នៅពេលដែលគ្រូបង្រៀនគោរពចំពោះសិស្សរបស់ពួកគេ ជាពិសេសសិស្សវ័យសិក្សានៅវិទ្យាល័យ ដោយការគោរពកាន់តែច្រើន ពួកគេទំនងជានឹងតបស្នងវិញដោយការគោរព និងសហការផងដែរ។

ឥទ្ធិពលកំពុងកើនឡើងលើសពីការរំពឹងទុករបស់យើង។ សកម្មភាពដែលស៊ីសង្វាក់គ្នា និងងាយស្រួលក្នុងការថែរក្សា បង្កើនឥទ្ធិពលកាន់តែច្រើនឡើង។ នៅក្នុងថ្នាក់រៀនទាំងអស់ យើងឃើញអត្រានៃការចូលរួមកាន់តែច្រើន។ ថ្នាក់រៀនខ្លះអាចឡើងដល់ ១០០%។ ជាប្រចាំខ្ញុំឃើញមុខថ្មីៗដែលស្ម័គ្រចិត្តក្នុងថ្នាក់ដើម្បីជួយមិត្តភក្តិរបស់ពួកគេ រួមចំណែកដល់ការពិភាក្សាក្នុងថ្នាក់ សួរសំណួរ និងខិតខំស្វែងយល់អំពីរបៀបបំពេញកិច្ចការ ឬលំហាត់មួយ។ វឌ្ឍនភាពដ៏គួរឱ្យរំភើបបំផុតនោះ គឺថាសិស្សានុសិស្ស បញ្ចេញមតិ និងគំនិតផ្ទាល់ខ្លួនរបស់ពួកគេ បន្តិចម្តងៗ។ យើងជាគ្រូបង្រៀន ធ្វើឱ្យពួកគេជក់ចិត្ត ដើម្បីជួយពួកគេក្នុងការបញ្ចេញមតិរបស់ពួកគេ និងកែលម្អដំណើរការគិតរបស់ពួកគេជាមួយនឹងមតិកែលម្អ និងការទទួលស្គាល់របស់យើងចំពោះការខិតខំរបស់ពួកគេ។ ជាចុងក្រោយ យើងបានឃើញថា សិស្សកាន់តែច្រើនមានឆន្ទៈចូលរួមសកម្មភាពក្នុងថ្នាក់រៀន សូម្បីតែវានៅតែមានលក្ខណៈមិនស្រួលក្តី។ បន្តិចម្តងៗ ពួកគេព្យាយាមអនុវត្ត ឬចូលរួម ជំនួសឱ្យការគេង ឬការចេញពីកន្លែងអង្គុយរបស់ពួកគេដើម្បីរំខានដល់ដំណើរការសិក្សា។ យើងសង្ឃឹមថា សមាសភាគទាំងនេះនឹងកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំមួយនៃវឌ្ឍនភាព ដើម្បីជួយឱ្យយើងសម្រេចគោលដៅរួមគ្នា។





## ម៉ោងដែលខ្ញុំចូលចិត្តបំផុតនៃសប្តាហ៍! ពីអ្នកស្ម័គ្រចិត្ត ភីស ខរ Lavaria Nazarino ខេត្តកំពង់ឆ្នាំង

«អ្នកគ្រូ! អ្នកគ្រូ! ថ្ងៃនេះ អ្នកគ្រូបង្រៀនសិល្បៈមែនទេ?» សិស្សថ្នាក់ទី៥ម្នាក់របស់ខ្ញុំស្រែកហៅខ្ញុំនៅពេលកំពុងបង្រៀន។ គាត់កំពុងក្រោកឈរនៅខាងក្រោយថ្នាក់រៀន គ្រវីដៃមកខ្ញុំដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់ខ្ញុំ។ ថ្វីបើគាត់គួរតែកំពុងអង្គុយលើកៅអីរបស់គាត់ចម្លងអក្សរនៅលើក្ដារខៀនក៏ដោយ ក៏មុខរបស់ខ្ញុំរីករាយជាមួយការញញឹមដ៏ធំមួយដែរ។

«ចាំ! គឺនៅទីនោះនៅម៉ោង ១» ខ្ញុំឆ្លើយជាភាសាខ្មែរជាមួយសំឡេងអាមេរិកដ៏គ្រោតគ្រាតរបស់ខ្ញុំ ដោយចង្អុលទៅទិសដៅទូទៅនៃកន្លែងជួបជុំរបស់យើង។ ខ្ញុំមិនសូវចាំឈ្មោះអគារទេ ប៉ុន្តែ ដល់ពេលនេះ សិស្សដឹងថាខ្ញុំកំពុងនិយាយសំដៅដល់បន្ទប់ប្រជុំគ្រូ។

«យេ៎!» សិស្សរបស់ខ្ញុំមួយចំនួនបានលាន់មាត់។ ទោះបីជាខ្ញុំដឹងថាមិនមែនពួកគេទាំងអស់គ្នានឹងបង្ហាញខ្លួនក្ដី ក៏ក្ដីរំភើបដែលកូនសិស្សរបស់ខ្ញុំបង្ហាញចំពោះក្លឹបតូចរបស់ខ្ញុំ បានធ្វើឱ្យបេះដូងខ្ញុំកក់ក្ដៅណាស់។

ខ្ញុំចាំបានថ្ងៃដែលខ្ញុំមានភាពក្លាហានទៅសុំកូនសោបន្ទប់ប្រជុំពីនាយកសាលាដើម្បីខ្ញុំអាចបង្រៀនក្លឹបសិល្បៈរបស់ខ្ញុំរៀងរាល់ថ្ងៃសុក្រ។ នាយកសាលារបស់ខ្ញុំហាក់ដូចជាមានការងឿងឆ្ងល់អំពីបំណងរបស់ខ្ញុំក្នុងការបង្រៀនសិល្បៈដល់សិស្សក្នុងម៉ោងសម្រាកអាហារថ្ងៃត្រង់ ពីព្រោះសាលាខ្ញុំមិនមានក្លឹប និងសកម្មភាពក្រោយម៉ោងសិក្សាទេ។ ប៉ុន្តែក្រោយពេលដែលគាត់យល់ពីគោលបំណងនៃក្លឹប និងគោលដៅរបស់ខ្ញុំ គាត់ក៏រីករាយក្នុងការប្រគល់កូនសោ និងគាំទ្រក្លឹបនេះ។

ចាប់តាំងពីពេលនោះមក ក្លឹបសិល្បៈរបស់ខ្ញុំបានដំណើរការរៀងរាល់ថ្ងៃសុក្រ ក្នុងម៉ោងចុងក្រោយនៃពេលសម្រាកពិសាអាហារថ្ងៃត្រង់។ ពីរបីសប្តាហ៍ដំបូង ខ្ញុំមានអារម្មណ៍ភ័យរន្ធត់បន្តិច ព្រោះមានសិស្សមកចូលរួមច្រើនពីថ្នាក់ទី៤ ទី៥ និង ទី៦ របស់ខ្ញុំ។ ខ្ញុំមានសម្ភារៈតិចតួច និងមិនសូវមានគំនិតច្រើនថាត្រូវបង្រៀនអ្វីទេ។ នៅថ្ងៃដំបូង ខ្ញុំបានបោះពុម្ពរូបភាពផ្ទះ និងហាងកាហ្វេស្អាតៗសម្រាប់ឱ្យពួកគេផាត់ពណ៌។ យើងថែមទាំងបានព្យាយាមបត់ក្រដាសធ្វើរូប (អូរីហ្គាមី) ជាមួយគ្នានៅសប្តាហ៍បន្ទាប់។ ប៉ុន្តែ ការបង្រៀនសិស្សបឋមសិក្សាប្រមាណ ៥០នាក់ឱ្យបត់ក្រដាស់ធ្វើសត្វក្រៀល គឺជាកិច្ចការដែលស្ទើរតែមិនអាចទៅរួច។ នៅទីបញ្ចប់ មានតែសិស្សបីនាក់ប៉ុណ្ណោះដែលទទួលបានជោគជ័យ។ ចាប់តាំងពីពេលនោះមក ខ្ញុំបានបង្រៀន និងលើកទឹកចិត្តពួកគេឱ្យគូររូបសត្វ ផ្កា ភ្នំ ផ្ទះ ។ល។ បន្តិចម្ដងៗខ្ញុំបានបង្កើន សម្ភារៈសិល្បៈរបស់ខ្ញុំ ដោយទិញខ្មៅដៃពណ៌ ក្រមួនពណ៌ និងប៊ិចពណ៌នៅពេលដែលខ្ញុំឃើញវាក្នុងតម្លៃសមរម្យ។ ថ្វីបើមានសិស្សមករៀងរាល់សប្តាហ៍តិចជាងខែទីមួយក្ដី ក៏ខ្ញុំបានសុំខ្លួនទៅនឹងទម្លាប់ថ្មីជាមួយសិស្សរបស់ខ្ញុំដែរ។ ពួកគេហាក់ដូចជាសប្បាយចិត្តក្នុងការចំណាយម៉ោងអាហារថ្ងៃត្រង់ចុងក្រោយជាមួយខ្ញុំ ដោយគូរតាមប្រធានបទនៃសម្រាប់សប្តាហ៍នីមួយៗ ហើយខ្ញុំរីករាយដែលអាចមានភាពស្និទ្ធស្នាលជាមួយសិស្សរបស់ខ្ញុំផងដែរ។

ចំពោះខ្ញុំ ក្លឹបសិល្បៈមិនមែនមានន័យត្រឹមតែជាការរៀនសិល្បៈប៉ុណ្ណោះទេ ប៉ុន្តែវាគឺជាកន្លែងមួយដែលផ្ដល់ឱ្យពួកគេនូវឱកាសដើម្បីបង្ហាញពីខ្លួនឯង ជំរុញខ្លួនឱ្យចេញពីផ្នត់គំនិតនៃបុគ្គលល្អឥតខ្ចោះ និងកសាងទំនុកចិត្តលើខ្លួនឯង និងការងាររបស់ពួកគេ។ ក្លឹបសិល្បៈរបស់ខ្ញុំនាំមកនូវសេចក្ដីរីករាយបំផុតនៅក្នុងមួយសប្តាហ៍ ហើយខ្ញុំមានមោទនភាពចំពោះសិស្សរបស់ខ្ញុំ និងការប្ដេជ្ញាចិត្តរបស់ពួកគេចំពោះក្លឹបនេះ។





# កម្មវិធីគម្រោងអភិវឌ្ឍន៍ខ្នាតតូច និងសមិទ្ធផល

អភិក្រម ភីស ខ័រ ចំពោះការអភិវឌ្ឍ គឺសំដៅជួយប្រជាជនពង្រឹងសមត្ថភាពរបស់ពួកគេដើម្បីដោះស្រាយតម្រូវការពិតប្រាកដរបស់សហគមន៍ដែលខ្លួនរស់នៅ កៀរគរធនធានសហគមន៍ និងពង្រឹងជំនាញ តាមរយៈការវិភាគដោយមានការចូលរួមដើម្បីសកម្មភាពសហគមន៍។ បន្ទាប់ពីការចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំ និងការគ្រប់គ្រងគម្រោងនៅភ្នំពេញ អ្នកស្ម័គ្រចិត្ត ភីស ខ័រ និងគ្រូដៃគូរបស់ពួកគេ បានសហការគ្នាយ៉ាងជិតស្និទ្ធលើការរៀបចំសរសេរសំណើគម្រោង និងការអនុវត្តគម្រោងនៅក្នុងសហគមន៍របស់ពួកគេ។ ក្នុងឆ្នាំ ២០២៥ មានសំណើគម្រោងដែលដឹកនាំដោយសហគមន៍ចំនួន ៩ ដែលត្រូវបានអនុម័តផ្តល់ជូនអ្នកស្ម័គ្រចិត្ត ភីស ខ័រ និងគ្រូដៃគូយកទៅអនុវត្តនៅសាលា ក្នុងខេត្តផ្សេងៗគ្នាចំនួន ៦។ ទឹកប្រាក់សរុបនៃសំណើគម្រោងទាំង ៩ គឺមានចំនួនប្រមាណ ៥៤.០៦៣ ដុល្លារ។ គម្រោងជំនួយហិរញ្ញប្បទានខ្នាតតូចរបស់ ភីស ខ័រ បានផ្តល់ថិការចំនួន ៣៩.៧៥០ ដុល្លារ ព្រមទាំងមានការចូលរួមវិភាគទានពីសហគមន៍ប្រហែល ១៤.៣១៦ ដុល្លារ ស្មើនឹង ២៦% នៃទឹកប្រាក់សរុប។ ខាងក្រោមនេះគឺជាគម្រោងដែលអ្នកស្ម័គ្រចិត្ត ភីស ខ័រ និងសាលាបានអនុវត្តៈ គម្រោងទីលានបាល់បោះ ចំនួន ២; គម្រោងកែលម្អបរិស្ថានសាលាចំនួន ៣; គម្រោងសួនដំណាំសាលាចំនួន ២ ;គម្រោងបន្ទប់ពិសោធន៍កុំព្យូទ័រចំនួន ១ ; និងគម្រោងទឹកស្អាត និងអនាម័យចំនួន ១។

## គម្រោងអភិវឌ្ឍន៍ខ្នាតតូចដែលដឹកនាំដោយសហគមន៍

### កែលម្អអនាម័យនៅក្នុងសហគមន៍ ដោយអ្នកស្ម័គ្រចិត្ត ភីស ខ័រ Anyar Bloom នៅខេត្តបាត់ដំបង

សាលាមធ្យមសិក្សាមួយនៅកម្ពុជា បានរកឃើញថាសាលាមានស្ថានីយ៍លាងសម្អាតដៃដែលលែងប្រើប្រាស់ និងអត្រាអវត្តមានសិស្សខ្ពស់ដោយសារជំងឺឆ្លង។ ជាការឆ្លើយតប សាលានិងអ្នកស្ម័គ្រចិត្ត បានរៀបចំផែនការមួយដែលមានបីផ្នែក ដើម្បីកែលម្អហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និងអនាម័យរបស់សាលា និងអប់រំសហគមន៍អំពីការលាងសម្អាតដៃ។ ជំហានដំបូង - ធ្វើឱ្យស្ថានីយ៍លាងសម្អាតដៃដំណើរការឡើងវិញ។ សាលាបានទទួលជំនួយហិរញ្ញប្បទានខ្នាតតូចដើម្បីសាងសង់ប៉មទឹកមួយ និងតភ្ជាប់វាទៅនឹងស្ថានីយ៍លាងសម្អាតដៃ និងបន្ទប់ទឹកមួយចំនួនដែលមិនបានប្រើ ដោយធ្វើឱ្យដំណើរការឡើងវិញ។ ម៉ាស៊ីនបូមទឹកមួយដែលប្រើបន្ទះសូឡាធានានូវអាយុកាលប្រើប្រាស់ប៉មទឹកបានយូរ ពោលគឺវានឹងមិនចាំបាច់ត្រូវបិទដោយសារបន្ទុកនៃវិក្កយបត្រអគ្គិសនី។ បន្ទាប់មក សាលាបានប្រមូលអ្នកស្ម័គ្រចិត្តដើម្បីលាងសម្អាត និងតុបតែងបរិវេណជុំវិញបន្ទប់ទឹក។ ពួកគេបានលាបពណ៌បន្ទប់ទឹកឡើងវិញ ដាំផ្កា និងជួសជុលទ្វារនិងដំបូលដែលច្រេះចាប់។



នៅពេលប្រព័ន្ធទឹកដំណើរការ និងកន្លែងអនាម័យត្រូវបានសម្អាត ជំហានចុងក្រោយគឺត្រូវធានាថាសិស្សានុសិស្ស (និងលោកគ្រូ អ្នកគ្រូ!) ដឹងពីពេលវេលានិងរបៀបប្រើប្រាស់ស្ថានីយ៍លាងសម្អាតដៃ។ នៅដើមឆ្នាំសិក្សាថ្មី គ្រូទាំងអស់បានទទួលវគ្គបណ្តុះបណ្តាលស្តីពីការលាងសម្អាតដៃ បន្ទាប់មកពួកគេនឹងបង្រៀនទៅដល់សិស្សានុសិស្សបន្ត។ សាលានឹងធ្វើសិក្ខាសាលាបែបនេះឡើងវិញជារៀងរាល់ឆ្នាំ ដើម្បីធានាថាក្រុមសិស្សថ្មីៗគ្រប់គ្នានឹងបន្តប្រើប្រាស់ស្ថានីយលាងសម្អាតដៃនេះ។







## គម្រោងកែលម្អសាលានិងការអប់រំ ដោយអ្នកស្ម័គ្រចិត្ត ភីស ខ័រ Victoria Centeno នៅខេត្តកំពង់ចាម

នៅសាលាបឋមសិក្សាជនបទមួយក្នុងខេត្តកំពង់ចាម សហគមន៍ រួមទាំងគ្រូបង្រៀន បុគ្គលិក និងសិស្សានុសិស្ស បានសហការគ្នាលើគម្រោងមួយដើម្បីលើកកម្ពស់បរិស្ថានសិក្សា។ គំនិតផ្តួចផ្តើមសំខាន់ៗ រួមមាន ការដំឡើងទូដាក់ឯកសារដើម្បីរៀបចំទុកដាក់ឯកសារឱ្យកាន់តែប្រសើរឡើងការពង្រីកបណ្ណាល័យជាមួយនឹងធ្នើរសៀវភៅថ្មី និងក្តារខៀនមួយ ការកែប្រែប្រព័ន្ធភ្លើងបំភ្លឺដើម្បីជួយបង្កើនការផ្តោតអារម្មណ៍និងការដាក់ឱ្យប្រើប្រាស់នូវសម្ភារៈបន្ថែមសម្រាប់ការរៀនភាសាអង់គ្លេសដើម្បីអភិវឌ្ឍអក្ខរកម្ម។ កិច្ចខិតខំនេះបានបង្ហាញនូវស្មារតីសាមគ្គីភាព និងការប្តេជ្ញាចិត្ត គួរឱ្យកោតសរសើររបស់សមាជិកទាំងអស់ដែលពាក់ព័ន្ធ។




លទ្ធផលនៃគម្រោងបានបង្ហាញនូវការកែលម្អយ៉ាងសំខាន់ក្នុងបរិស្ថានសាលាដែលជួយសម្រួល ដល់ការធ្វើកិច្ចតែងការបង្រៀនកាន់តែងាយស្រួលសម្រាប់គ្រូបង្រៀននិងលើកទឹកចិត្តការប្រើប្រាស់បណ្ណាល័យក្នុងចំណោមសិស្សានុសិស្ស។ លក្ខខណ្ឌថ្នាក់រៀនកាន់តែប្រសើរឡើង រួមទាំងភ្លើងបំភ្លឺល្អជាងមុន និងសម្ភារៈបំពេញបន្ថែម បានជំរុញការចូលរួម និងការចាប់អារម្មណ៍របស់សិស្ស។ គំនិតផ្តួចផ្តើមនេះ បានបណ្តុះគំនិតច្នៃប្រឌិត កិច្ចសហការ និងជំនាញជាក់ស្តែងក្នុងការគ្រប់គ្រងគម្រោងសម្រាប់អ្នកចូលរួមទាំងអស់ ដោយសិស្សបំពេញតួនាទីយ៉ាងសកម្មក្នុងការគ្រប់គ្រងធនធាន។ និរន្តរភាពត្រូវបានផ្តល់អាទិភាពតាមរយៈការប្រើប្រាស់សម្ភារៈដែលធនបានយូរនិងការកំណត់តួនាទីថែទាំជាប្រចាំដើម្បីធានាឱ្យបាននូវអត្ថប្រយោជន៍យូរអង្វែង។បញ្ហាប្រឈមទាំងឡាយត្រូវបានដោះស្រាយតាមរយៈភាពបត់បែន និងការប្តេជ្ញាចិត្តពីសហគមន៍ដែលនៅទីបំផុត បង្កើនទំនុកចិត្ត និងសមត្ថភាពភាពដឹកនាំសម្រាប់គម្រោងនាពេលអនាគត។

ខ្ញុំពិតជាមានអំណរគុណយ៉ាងជ្រាលជ្រៅដែលបានចូលរួមជាផ្នែកមួយនៃគម្រោងនេះ។ ការមើលឃើញពីការលះបង់ គំនិតច្នៃប្រឌិត និងស្មារតីសាមគ្គីភាពរបស់សហគមន៍សាលា គឺជាបទពិសាធន៍ដ៏មានតម្លៃ និងធ្វើឱ្យខ្ញុំពេញចិត្តក្រៃលែង ហើយប្រការដែលអាចចូលរួមចំណែកដល់កិច្ចខិតខំមួយដែលផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់ការសិក្សានិងការរីកចម្រើនរបស់សិស្សានុសិស្សគឺជាបទពិសោធន៍មួយដែលខ្ញុំនឹងចងចាំជារៀងរហូត។ គម្រោងនេះបង្ហាញនូវអំណាចនៃការខិតខំរបស់សហគមន៍ តាមរយៈកិច្ចសហការ គំនិតច្នៃប្រឌិត និងការតស៊ូ គ្រូបង្រៀន បុគ្គលិក និងសិស្សានុសិស្ស បានបម្លែងបរិយកាសសិក្សារបស់ពួកគេទៅជាកន្លែងមួយដែលជំរុញទឹកចិត្ត គាំទ្រ និងបំផុសគំនិត។ វាគឺជាសក្ខីភាព មួយនៃអ្វីដែលអាចសម្រេចបាន នៅពេលដែលសហគមន៍សាលាមួយរួបរួមគ្នាជាមួយនឹងការលះបង់ សាមគ្គីភាព និងចក្ខុវិស័យរួមមួយដើម្បីការសិក្សា។






# បន្ទប់ពិសោធន៍កុំព្យូទ័រ ពីអ្នកស្ម័គ្រចិត្ត ភីស ខ័រ Yondonjamts Jigjidsuren នៅខេត្តបន្ទាយមានជ័យ

ទ្រព្យដ៏សំខាន់បំផុតមួយដែលត្រូវមាននៅក្នុងពិភពលោកដែលកំពុងអភិវឌ្ឍនិងកំពុងផ្លាស់ប្តូររបស់យើង គឺលទ្ធភាព ប្រើប្រាស់កុំព្យូទ័រនិងជំនាញបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍(ITC)។ នាពេលបច្ចុប្បន្នអ្នកប្រហែលជាគិតថាមនុស្សគ្រប់គ្នាមានលទ្ធភាពប្រើប្រាស់កុំព្យូទ័រ អ៊ីនធឺណិត និងទូរស័ព្ទឆ្លាតវៃបាន ។ ប៉ុន្តែ នៅតែមានមនុស្សជាច្រើនដែលមិនមានលទ្ធភាព។ បញ្ហានេះកើតមានច្រើនបំផុតនៅសាលារៀនតាមជនបទ ដែលនៅទីនោះ គេអាចឃើញមានភាពខុសគ្នានៅក្នុងធនធាននិងកង្វះលទ្ធភាពដែលអាចពង្រីកគម្លាតរវាងសិស្សនៅទីក្រុង និងសិស្សនៅតាមជនបទ។



សាលារបស់ខ្ញុំ បានចាប់ផ្តើមគិតអំពីវិធីដើម្បីកែលម្អគុណភាពអប់រំតាមរបៀបផ្សេងៗ។ យើងបានដឹងថាអ្វីៗគ្រប់យ៉ាងគឺផ្សារភ្ជាប់ទៅនឹងការអប់រំ មិនថាជាធនធាន ឬការទទួលបានអាហារូបត្ថម្ភជាមូលដ្ឋាន ការថែទាំសុខភាព អនាម័យ ឬជំនាញកុំព្យូទ័រនោះទេ។ ប្រការដែលគួរឱ្យកត់សម្គាល់ គឺថាសាលាខ្ញុំមិនមានបន្ទប់ពិសោធន៍កុំព្យូទ័រទេ ប៉ុន្តែ សាលា ២ ដែលនៅជុំវិញនោះមាន។ ក្រោយពេលយើងសម្រេចចិត្តសាងសង់បន្ទប់ពិសោធន៍កុំព្យូទ័រថ្មីមួយ គ្រូដៃគូខ្ញុំ និងខ្ញុំបានចាប់ផ្តើមគិតអំពីជំហានដែលយើងត្រូវធ្វើដើម្បីបង្កើតបន្ទប់ពិសោធន៍កុំព្យូទ័រនេះ។ ប៉ុន្តែ យើងត្រូវបានគេប្រាប់ថា នេះគឺជាកិច្ចការដ៏ធំមួយ ជាពិសេសគឺពាក់ព័ន្ធនឹងថ្លៃចំណាយ។ ខ្ញុំមិនចង់បោះបង់ចោលគំនិតនេះទេ ដូច្នេះ នៅពេលដែលចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំនិងគ្រប់គ្រងគម្រោង ភីស ខ័រ ខ្ញុំដឹងថាខ្ញុំមានការគាំទ្រពីនាយកសាលារបស់ខ្ញុំក្នុងការអភិវឌ្ឍបន្ទប់ពិសោធន៍កុំព្យូទ័រនោះ។

ក្រោយពេលត្រឡប់មកពីការចូលរួមវគ្គបណ្តុះបណ្តាលវិញនៅខែមីនា ឆ្នាំ២០២៤ យើងបានសម្រេចចិត្តកែប្រែថ្នាក់រៀនទំនេរមួយដែលពីមុនប្រើសម្រាប់ធ្វើឃ្លាំង ជំនួសការសាងសង់បន្ទប់ថ្មីមួយ។ ដោយសហការជាមួយនាយកសាលាខ្ញុំ និងគ្រូដៃគូ យើងបានចាប់ផ្តើមសម្អាត និងរៀបចំបរិវេណនោះឡើងវិញ។ ដើម្បីដោះស្រាយកង្វះថវិកា យើងបានស្វែងរកវិភាគទានយ៉ាងសកម្ម ទន្ទឹមនឹងនោះសមាជិកសហគមន៍បានចូលរួមជួយដោយរួមមានជាងភ្លើង និងជាងលាបថ្នាំពណ៌។ ក្នុងពេលជាមួយគ្នានេះ គ្រូបង្រៀនបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ITC) ម្នាក់បានឃើញហាងលក់កុំព្យូទ័រមួយនៅកម្ពុជា ដែលយើងបានទិញ កុំព្យូទ័រចំនួន ២០ គ្រឿងក្នុងតម្លៃសមរម្យដែលត្រូវបានបញ្ចុះតម្លៃសម្រាប់ការអប់រំ។ កិច្ចខិតខំរៃអង្គាសថវិកា បានបញ្ចប់ដោយជោគជ័យក្នុងរយៈពេល ៣ខែ ដែលអនុញ្ញាតឱ្យកុំព្យូទ័រទាំងនេះត្រូវបានដឹកជញ្ជូនទៅកាន់ខេត្តបន្ទាយមានជ័យ នេះជាជំហានដ៏សំខាន់មួយក្នុងការអភិវឌ្ឍគម្រោង។

បន្ទាប់ពីបានទទួលអំណោយហិរញ្ញប្បទានពី ភីស ខ័រ នៅក្នុងឆ្នាំដដែល បន្ទប់ពិសោធន៍កុំព្យូទ័រមួយបានដំណើរការពេញលេញជាមួយនឹងកុំព្យូទ័រចំនួន ២០ គ្រឿង បំពាក់ដោយម៉ាស៊ីនបញ្ចាំង និងបច្ចេកវិទ្យាចាំបាច់សម្រាប់បរិស្ថានសិក្សាពេញលេញមួយ។ បន្ទាប់ពីបានរៀបចំរួច គ្រូបង្រៀនផ្នែកព័ត៌មានវិទ្យាបានធ្វើតេស្តឧបករណ៍ទាំងនោះ និងរៀបចំសិក្ខាសាលាសម្រាប់មាតិកាមេរៀន។ សិស្សថ្នាក់ទី១០ គឺជាក្រុមដំបូងគេដែលបានប្រើប្រាស់បន្ទប់ពិសោធន៍នេះ ដោយមានសិស្សជាង ៣០នាក់បានរៀនវាយអក្សរ ការបង្កើតឯកសារបង្ហាញ PowerPoint និងការគ្រប់គ្រងឯកសារក្នុងរយៈពេលមួយឆមាស។ លើសពីនេះ ប្រធានសហគមន៍ម្នាក់បានរៀបចំសិក្ខាសាលាសម្រាប់គ្រូនិងបុគ្គលិកដែលមានវ័យចាស់ជាង ដែលអនុញ្ញាតឱ្យគ្រូអប់រំជាង ២០នាក់ ដែលមានអាយុពី ៣៥ ដល់ ៥០ឆ្នាំ អភិវឌ្ឍជំនាញ





ប្រើប្រាស់កុំព្យូទ័ររបស់ពួកគេតាមរយៈវគ្គសិក្សារយៈពេលមួយម៉ោងក្នុងមួយសប្ដាហ៍។ គំនិតផ្ដួចផ្ដើមដែលបានចាប់ផ្ដើមជាក្ដីស្រមៃមួយ បានចូលរួមប្រកបដោយជោគជ័យជាមួយសិស្សជាង ៦០ នាក់ និងគ្រូបង្រៀនចំនួន ២០ នាក់ ដោយបំពេញបំណងប្រាថ្នាក្នុងការបង្កើតឥទ្ធិពលដ៏សំខាន់មួយលើសពីការបង្រៀនភាសាអង់គ្លេសនៅក្នុងសហគមន៍។

## ទីលានបាល់បោះ ពីអ្នកស្ម័គ្រចិត្ត ភីស ខ័រ Alexandra Baker នៅខេត្តបន្ទាយមានជ័យ

នៅសាលាបឋមសិក្សាមួយក្នុងខេត្តបន្ទាយមានជ័យ គេសង្កេតឃើញថាសិស្សានុសិស្សចូលចិត្តលេងកីឡាក្នុងពេលសម្រាក និងក្រោយពេលចប់ម៉ោងរៀន ប៉ុន្តែ នៅពេលមានភ្លៀងធ្លាក់ខ្លាំង និងជន់លិចសាលាពួកគេមិនអាចលេងបាន។ ការហាត់ប្រាណមិនត្រឹមតែសំខាន់សម្រាប់ការជំរុញសុខភាពប៉ុណ្ណោះទេ ប៉ុន្តែ កីឡាក៏បង្រៀនសិស្សអំពីការធ្វើការជាក្រុម កិច្ចសហប្រតិបត្តិការ និងការប្រាស្រ័យទាក់ទងថែមទៀតផង។ អ្នកស្ម័គ្រចិត្ត ភីស ខ័រ និងនាយកសាលាបានធ្វើការរួមគ្នាដើម្បីបង្កើតទីលានបាល់បោះដែលមានសព្វថ្ងៃនេះ។ ពួកគេទាំងពីរ បានចូលរួមសិក្ខាសាលាស្ដីពីការរៀបចំ និងគ្រប់គ្រងគម្រោងដែលបានរៀបចំដោយទីភ្នាក់ងារ ភីស ខ័រ ហើយភ្លាមៗក្រោយពេលនោះ ក៏បានចាប់ផ្ដើមរៀបចំគូរប្លង់សម្រាប់ទីលានបាល់បោះនោះ។



បន្ទាប់ពីការរៃអង្គាសថវិកាបានបញ្ចប់ ទីលានបាល់បោះនេះត្រូវបានសាងសង់ក្នុងរយៈពេល ១០ ថ្ងៃ ដោយជួលជាងពី ក្នុងមូលដ្ឋានដែលនាយកសាលាស្គាល់។ សាលាបានសាងសង់កន្ត្រកបាល់បោះពីរប្រភេទ ពោលគឺមួយមានកម្ពស់តាមស្តង់ដារ និងមួយទៀតមានកម្ពស់ទាបជាង ដូច្នេះសិស្សវ័យក្មេងជាងក៏អាចប្រើទីលានបានផងដែរ។ សាលាក៏បានសាងសង់កៅអីអង្គុយមើលដ៏ធំមួយផងដែរ ដើម្បីឱ្យសិស្សអាចអង្គុយមើលមិត្តភក្តិពួកគេលេងនៅលើទីលាន។

ក្រោយពេលដែលទីលានបាល់បោះត្រូវបានសាងសង់រួចរាល់ គេឃើញច្បាស់ណាស់ថាសិស្សានុសិស្ស និងគ្រូមានក្តីរំភើបអំពីទីលានថ្មីនេះ។ បន្ទាប់ពីអ្នកស្ម័គ្រចិត្តភីសខ័រ និងសាលារៀនបានទិញបាល់បោះរួច សិស្សបានមកការិយាល័យគ្រូយ៉ាងប្រញាប់ប្រញាល់រៀងរាល់ថ្ងៃ ដើម្បីចុះឈ្មោះសុំយកបាល់។ ម្យ៉ាងទៀត គ្រូមួយក្រុមមានបីនាក់បានសុំឱ្យអ្នកស្ម័គ្រចិត្ត ភីស ខ័រ បង្រៀនលេងបាល់បោះជាមួយគ្នា និងហាត់ប្រាណនៅលើទីលាននៅសាលាក្រោយម៉ោងសិក្សា ។ ប្រការនេះបានក្លាយជាសកម្មភាពធម្មតាចាប់ពីម៉ោង ៥:០០-៥:៣០ ល្ងាចជារៀងរាល់ថ្ងៃ ដែលបានជំរុញ ដល់សិស្សមួយចំនួនឱ្យនៅលេងបន្ទាប់ពីម៉ោងរៀនផងដែរ។ ស្រដៀងគ្នានេះដែរ អ្នកស្ម័គ្រចិត្ត ភីស ខ័រ បានរៀបចំវគ្គ បណ្ដុះបណ្ដាលខ្លីមួយ ដើម្បីណែនាំលំហាត់បាល់បោះដល់គ្រូបង្រៀនមកពីសាលាបឋមសិក្សាមួយចំនួន។ គ្រូបង្រៀនទាំងនោះទទួលបានឯកសារមួយកញ្ចប់ដែលបង្កើតឡើងដោយអ្នកស្ម័គ្រចិត្ត ភីស ខ័រ រួមមានល្បែង និងសកម្មភាពផ្សេងៗដែលអាចលេងនៅលើទីលាននេះដែរ ទាំងនេះនឹងបំពេញបន្ថែមលើមគ្គុទេសក៍អប់រំកាយពីក្រសួងអប់រំ យុវជន និងកីឡា។ ក្រោយពេលបញ្ចប់វគ្គបណ្ដុះបណ្ដាលនេះ គ្រូបង្រៀនជាច្រើនបានអនុវត្តបច្ចេកទេសទាំងនេះក្នុងថ្នាក់អប់រំកាយរបស់ពួកគេ។





សមត្ថភាពនិងជំនាញជាក់ស្ដែងបំផុតដែលបានកសាង គឺស្មារតីធ្វើការជាក្រុម ការទទួលខុសត្រូវ និងកិច្ចសហប្រតិបត្តិការក្នុងចំណោមសិស្សានុសិស្ស។ សិស្សបានរៀនពីរបៀបទទួលខុសត្រូវលើបាល់ ដូចជាការធ្វើឱ្យប្រាកដថាបាល់ទាំង ១០ ស្ថិតនៅក្នុងកន្ត្រកមុនពេលចាក់សោរទុក និងចុះហត្ថលេខាឈ្មោះពួកគេនៅក្នុងសៀវភៅនៅពេលពួកគេយកបាល់ចេញ។ ដំបូងឡើយ សិស្សបានឈ្លោះប្រកែកគ្នាអំពីប្រការដែលថាតើអ្នកណាបានប្រើបាល់ ប៉ុន្តែ ក្រោយមក បន្តិចម្តងៗពួកគេបានរៀនពីរបៀបសហការ និងចែករំលែកដើម្បីលេងជាមួយគ្នា។

សកម្មភាពសំខាន់ៗនៅលើទីលាន គឺថ្នាក់អប់រំកាយប្រចាំសប្តាហ៍ ការលេងបាល់ពេលទំនេរ ការចុះឈ្មោះទុក/យកចេញបាល់បោះ និងលំហាត់របស់គ្រូ។ ជួនកាល ព្រឹត្តិការណ៍ផ្សេងៗក៏ត្រូវបានធ្វើឡើងនៅលើទីលាននេះផងដែរ ពីព្រោះវាផ្តល់កន្លែងគ្រប់គ្រាន់សម្រាប់ការជួបជុំធំៗ ក៏ដូចជាការនៅខ្ពស់លើទឹកជំនន់ក្នុងរដូវវស្សា។ អំណោយហិរញ្ញប្បទាននេះ បានផ្តល់ឥទ្ធិពលលើសិស្សជាង ៩០០ នាក់ ក្នុងការគាំទ្រដល់សុខភាពរាងកាយ និងការកសាងសមត្ថភាពពួកគេ ក៏ដូចជាគ្រូបង្រៀនជាង ៣០ នាក់ ដែលចូលរួមក្នុងផ្នែកខ្លះនៃអំណោយហិរញ្ញប្បទាន ឬក្នុងវគ្គបណ្តុះបណ្តាល។ ដោយសារគេរំពឹងថាសិស្សនឹងចែករំលែកនូវអ្វីដែលពួកគេបានរៀននៅសាលាជាមួយក្រុមគ្រួសារ និងមិត្តភក្តិរបស់ពួកគេ គេបានសន្មត់ថាមានអ្នកទទួលផលដោយប្រយោលជាង ១.៨០០ នាក់ពីអំណោយហិរញ្ញប្បទាននេះ។

ទីលាននេះទទួលបានការគាំទ្រពីរដ្ឋាភិបាលថ្នាក់មូលដ្ឋាននិងថ្នាក់ជាតិ ប៉ុន្តែ គេមើលឃើញច្បាស់ថាដោយសារការខិតខំរបស់នាយកសាលា និងសាលា ក្តីស្រមៃអំពីទីលានបាល់បោះមួយបានក្លាយជាការពិត។

# ការត្រៀមរៀបចំជាមុនសម្រាប់ការបម្រើការងារ

នៅពេលមកដល់កម្ពុជា អ្នកស្ម័គ្រចិត្ត ភីស ខ័រ ទទួលបានការបណ្តុះបណ្តាលដ៏ទូលំទូលាយផ្នែកភាសា វប្បធម៌ សុខភាព សុវត្ថិភាព និងបច្ចេកទេស ។ ភីស ខ័រ ផ្តល់ឱកាសបណ្តុះបណ្តាលជូនដល់អ្នកស្ម័គ្រចិត្តដើម្បីកែលម្អជំនាញភាសានិងជំនាញបច្ចេកទេសរបស់ពួកគេនៅក្នុងអំឡុងពេលបម្រើការងារជាអ្នកស្ម័គ្រចិត្ត ភីស ខ័រ ។

ការបណ្តុះបណ្តាលសម្រាប់អ្នកស្ម័គ្រចិត្ត

| | |
|---|---|
| ការបណ្តុះបណ្តាលបឋម (PST) | ក្រោយការមកដល់ |
| ការបណ្តុះបណ្តាលក្នុងពេលបម្រើការងារ (IST) | ៣ ខែ ក្រោយពេលទៅសហគមន៍ដែលគាត់រស់នៅ |
| ការបណ្តុះបណ្តាលស្តីពីការរៀបចំនិងគ្រប់គ្រងគម្រោង (PDM) | ៥ ខែ ក្រោយពេលទៅសហគមន៍ដែលគាត់រស់នៅ |
| ការបណ្តុះបណ្តាលពាក់កណ្តាលការបំពេញការងារ (MST) | ១២ ខែក្រោយពេលទៅសហគមន៍ដែលគាត់រស់នៅ |
| សិក្ខាសាលាបញ្ចប់ការបម្រើការងារ (COS) | ២០ ខែក្រោយពេលទៅសហគមន៍ដែលគាត់រស់នៅ |

## ការបណ្តុះបណ្តាលបឋម (PST) សម្រាប់ក្រុម K១៧ នៅខែសីហា ឆ្នាំ២០២៥

សិក្ខាកាមចំនួន ២៥ នាក់នៃក្រុមអ្នកស្ម័គ្រចិត្ត ភីស ខ័រ កម្ពុជាទី១៧ (K១៧) បានមកដល់នៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៥ ហើយបានចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលបឋមរយៈពេល ១០ សប្តាហ៍ រហូតដល់ថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៥។ ពួកគេរៀន និងរស់នៅស្រុកត្រាំកក់ ខេត្តតាកែវ ដោយមានការគាំទ្រពីអាជ្ញាធរមូលដ្ឋាន សហគមន៍ គ្រួសារម្ចាស់ផ្ទះ និងបុគ្គលិក ភីស ខ័រ។ ក្រោយការបញ្ចប់វគ្គបណ្តុះបណ្តាលនេះ សិក្ខាកាម K១៧ បានធ្វើសច្ចាប្រណីធានដើម្បីចូលបម្រើការងារជាអ្នកស្ម័គ្រចិត្ត ភីស ខ័រ នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៥។

ប្រធានបទដែលបានបង្រៀននៅក្នុងវគ្គបណ្តុះបណ្តាលបឋម រួមមានជំនាញទន់ និងជំនាញរឹង ដែលនឹងជួយអ្នកស្ម័គ្រចិត្តក្នុងការបម្រើការងារក្នុងអាជីពរបស់ពួកគេ។ តាមរយៈការអភិវឌ្ឍជំនាញបច្ចេកទេសថ្មីៗ ក្នុងការបង្រៀនភាសាអង់គ្លេសជំនាញអន្តរវប្បធម៌ និងជំនាញភាសាខ្មែរ សមត្ថភាពក្នុងការសម្របខ្លួនទៅនឹងការបម្រើការងារ និងសហគមន៍ សុខភាព សុវត្ថិភាព និងសន្តិសុខផ្ទាល់ខ្លួន និងឆន្ទៈក្នុងការរៀនសូត្រ និងសហការជាមួយអ្នកដទៃ អ្នកស្ម័គ្រចិត្តអាចបង្កើនសមត្ថភាព និងបទពិសោធន៍របស់ពួកគេនៅនឹងកន្លែង។ ការបណ្តុះបណ្តាលបឋម ពិចារណាយ៉ាងមធ្យ័តអំពីជំនាញនិងទឹកចិត្តរបស់អ្នកស្ម័គ្រចិត្តជាមួយក្រុមបណ្តុះបណ្តាលប្រកបដោយសមត្ថភាពនៃអ្នកអប់រំដែលមានបទពិសោធន៍។ ក្រុម K១៧ បានបញ្ចប់ការបណ្តុះបណ្តាលរបស់ពួកគេប្រកបដោយជោគជ័យដោយមានទំនុកចិត្ត ហើយនឹងបន្តការងាររបស់ពួកគេនៅសហគមន៍អចិន្ត្រៃយ៍នៅក្នុងខេត្តចំនួន ១៣ ផ្សេងៗគ្នាទូទាំងប្រទេសកម្ពុជា។











## ការបណ្តុះបណ្តាលក្នុងពេលបម្រើការងារ( IST ) សម្រាប់ក្រុម K១៦ នៅខែមករា ឆ្នាំ ២០២៥

គោលបំណងនៃវគ្គការបណ្តុះបណ្តាលក្នុងពេលបម្រើការងារសំដៅគាំទ្រដល់អ្នកស្ម័គ្រចិត្តដោយផ្តល់ការបណ្តុះបណ្តាលបន្ថែមផ្នែកភាសា បច្ចេកទេស និងវប្បធម៌ ក៏ដូចជាជួយសម្រួលការពិភាក្សាអំពីការងារ និងការលើកទឹកចិត្ត។ នេះគឺជាឱកាសមួយសម្រាប់ឱ្យអ្នកស្ម័គ្រចិត្តស្វែងរកឃើញឡើងវិញពីការជំរុញទឹកចិត្តរបស់ពួកគេរកឃើញឡើងវិញនូវកម្លាំងចិត្ត និងការប្តេជ្ញាចិត្តចំពោះការបម្រើការងាររបស់ខ្លួនក៏ដូចជាពង្រឹងសមត្ថភាពក្នុងការសហការជាមួយភាគីពាក់ព័ន្ធក្នុងសហគមន៍ដោយផ្អែកលើវិធីសាស្ត្រដែលមានចីរភាព។ ក្រុមអ្នកស្ម័គ្រចិត្តមានសេចក្តីរំភើបយ៉ាងខ្លាំងដែលបានមកជួបជុំគ្នា និងសហការគ្នាជាថ្មីម្តងទៀត និងមានចិត្តរីករាយយ៉ាងខ្លាំងចំពោះការវិលត្រឡប់ទៅកាន់សាលារបស់ពួកគេវិញនៅទូទាំងប្រទេសកម្ពុជា។





























## ការបណ្តុះបណ្តាលស្តីពីការរៀបចំ និងគ្រប់គ្រងគម្រោង (PDM) សម្រាប់អ្នកស្ម័គ្រចិត្ត និងគ្រូដៃគូពួកគេក្នុងខែមីនា ឆ្នាំ២០២៥

អ្នកស្ម័គ្រចិត្ត ភីស ខ័រ និងគ្រូដៃគូរបស់ពួកគេ បានរៀនជំនាញ និងយុទ្ធសាស្ត្រថ្មីៗជាមួយគ្នាអំពីរបៀបកំណត់តម្រូវការរបស់សហគមន៍ពួកគេ របៀបដោះស្រាយបញ្ហាប្រឈមស្មុល និងរបៀបរៀបចំគម្រោងដែលដឹកនាំដោយសហគមន៍ដើម្បីអនុវត្តនៅសហគមន៍របស់ពួកគេ។ ជាលទ្ធផល អ្នកស្ម័គ្រចិត្តភីសខ័រ និងគ្រូដៃគូ មានការយល់ដឹងរួមអំពីសហគមន៍របស់ពួកគេ និងត្រូវបានបំពាក់ដោយឧបករណ៍នានាដើម្បីរៀបចំសំណើគម្រោង និងគ្រប់គ្រងគម្រោងសហគមន៍រួមគ្នា។

## ការបណ្តុះបណ្តាលពាក់កណ្តាលការបំពេញការងារ(MST )សម្រាប់ក្រុម K១៦ នៅក្នុងខែវិច្ឆិកា ឆ្នាំ ២០២៥









## សិក្ខាសាលាបញ្ចប់ការបម្រើការងារ (COS ) សម្រាប់ក្រុម K១៥ ក្នុងខែកញ្ញា ឆ្នាំ ២០២៥






## វគ្គបណ្តុះបណ្តាលសម្រាប់សមាជិកសហគមន៍

ទីភ្នាក់ងារ ភីស ខ័រ កម្ពុជា ក៏ផ្តល់ការបណ្តុះបណ្តាលជូនសមាជិកសហគមន៍ ដែលនឹងធ្វើជាម្ចាស់ផ្ទះ និងផ្តល់ការគាំទ្រដល់អ្នកស្ម័គ្រចិត្ត រួមមានគ្រួសារម្ចាស់ផ្ទះ គ្រូ នាយកសាលា និងគ្រូដៃគូផងដែរ។

## ជំនួបជាមួយគ្រួសារម្ចាស់ផ្ទះ សម្រាប់ក្រុមអ្នកស្ម័គ្រចិត្តថ្មី ក្នុងខែកញ្ញា ឆ្នាំ២០២៥



ទីភ្នាក់ងារ ភីស ខ័រ បានអញ្ជើញសមាជិកគ្រួសារម្ចាស់ផ្ទះ ចំនួន ៥២ នាក់មកពីខេត្តចំនួន ១១ នៅកម្ពុជារួមមាន៖ សៀមរាប កំពង់ធំ កំពង់ឆ្នាំង កំពង់ស្ពឺ បាត់ដំបង កំពង់ចាម ព្រៃវែង ស្ទឹងត្រែង ក្រចេះ តាកែវ និងកំពត។ ពួកគេបានជួបជុំគ្នាដើម្បីស្វែងយល់អំពីតួនាទី និងការទទួលខុសត្រូវរបស់ពួកគេក្នុងការបង្កើតបរិស្ថានគាំទ្រ សម្រាប់ អ្នកស្ម័គ្រចិត្ត របស់ពួកគេ។ ជំនួបនេះ គឺសំដៅត្រៀមលក្ខណៈគ្រួសារម្ចាស់ផ្ទះសម្រាប់បំពេញតួនាទីពួកគេក្នុងការគាំទ្រអ្នកស្ម័គ្រចិត្ត ភីស ខ័រ និងដើម្បីជំរុញបទពិសោធន៍ផ្លាស់ប្តូរវប្បធម៌ប្រកបដោយជោគជ័យមួយ ប្រព័ន្ធគាំទ្រ និងការប្រាស្រ័យទាក់ទង។

## ការបណ្តុះបណ្តាលគ្រូដៃគូកម្រិតបឋមសិក្សា ក្នុងខែកញ្ញា ឆ្នាំ២០២៥

គ្រូបង្រៀនបឋមសិក្សាដែលនឹងធ្វើការជាមួយអ្នកស្ម័គ្រចិត្តនៅតាមសាលារៀនពួកគេ បានចូលរួមក្នុងសិក្ខាសាលាមួយរយៈពេលពីរថ្ងៃ ដែលផ្តោតលើការបង្រៀនភាសាអង់គ្លេសសម្រាប់សិស្សបឋមសិក្សា។ ក្នុងអំឡុងពេលសិក្ខាសាលានេះ ពួកគេបានសិក្សាអំពីកម្មវិធីសិក្សាភាសាអង់គ្លេសកម្រិតបឋមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា និងបានស្វែងយល់ អំពីបច្ចេកទេសជាមូលដ្ឋានសម្រាប់ការបង្រៀនភាសាអង់គ្លេស វិធីសាស្រ្តបង្រៀនរួមគ្នាជាមួយអ្នកស្ម័គ្រចិត្ត និងវិធីសាស្រ្តវាយតម្លៃការបង្រៀន។ អ្នកចូលរួមបានរៀបចំផែនការបង្រៀន និងបង្រៀនរួមគ្នាជាមួយអ្នកស្ម័គ្រចិត្តដើម្បីអនុវត្តចំណេះដឹងថ្មីរបស់ពួកគេជាក់ស្តែង។









# សិក្ខាសាលាស្តីពី គណៈគ្រប់គ្រងសាលា និងគ្រូដៃគូ ខែកញ្ញា ឆ្នាំ២០២៥



សិក្ខាសាលាស្តីពីគណៈគ្រប់គ្រងសាលា និងគ្រូដៃគូគឺជាព្រឹត្តិការណ៍ដ៏សំខាន់មួយ ដែលត្រូវបានរៀបចំដើម្បីលើកកម្ពស់កិច្ចសហការរវាងអ្នកស្ម័គ្រចិត្ត ភីស ខ័រ និងគ្រូដៃគូក្នុងមូលដ្ឋានរបស់ពួកគេ។ សិក្ខាសាលានេះ ដើរតួនាទីជាវេទិកាមួយសម្រាប់បង្កើនការយល់ដឹងពីគ្នាទៅវិញទៅមក ការចែករំលែកបទពិសោធន៍គ្នា និងការអភិវឌ្ឍយុទ្ធសាស្ត្រដែលសមស្របរវាងគោលដៅរបស់ ភីស ខ័រ នឹងតម្រូវការរបស់សហគមន៍ដែលពួកគេបម្រើការងារ។

នៅក្នុងវិស័យអភិវឌ្ឍន៍ផ្នែកអប់រំ កិច្ចសហការរវាងនាយកសាលាក្នុងមូលដ្ឋាន គ្រូដៃគូ និងអ្នកស្ម័គ្រចិត្ត ភីស ខ័រ មានសារៈសំខាន់យ៉ាងខ្លាំង សម្រាប់ការលើកកម្ពស់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងការកែលម្អគុណភាពនៃការបង្រៀនភាសាអង់គ្លេស។ របាយការណ៍នេះ គូសបង្ហាញនូវសិក្ខាសាលានាពេលថ្មីៗមួយ ដែលបានប្រមូលផ្តុំដោយនាយកសាលា និងគ្រូដៃគូមកពីខេត្តផ្សេងៗ ដូចជា៖ កំពង់ឆ្នាំង កំពង់ស្ពឺ សៀមរាប កំពង់ធំ បាត់ដំបង កំពង់ចាម ព្រៃវែង ស្ទឹងត្រែង កំពត តាកែវ និងក្រចេះ ដែលបង្ហាញពីភាពជាដៃគូប្រកបដោយជោគជ័យ ការអនុវត្តបែបនវានុវត្តន៍ និងគោលដៅនាពេលអនាគត។

លោកស្រី ព្រំ សុឡុន នាយិកាវិទ្យាល័យ ហ៊ុនសែន រលួស បានចែករំលែកបទពិសោធន៍ដ៏មានតម្លៃរបស់គាត់ក្នុងការគ្រប់គ្រងអ្នកស្ម័គ្រចិត្តប្រកបដោយប្រសិទ្ធភាព។ គាត់បានលើកឡើងថា នៅពេលទទួលអ្នកស្ម័គ្រចិត្តមកបម្រើការនៅ សាលា គួរតែចាត់ទុកពួកគេថាជាសមាជិកម្នាក់នៃក្រុមការងារ សាលាត្រូវមានការទំនាក់ទំនងជាប្រចាំ លើកទឹកចិត្តពួកគេ និងដោះស្រាយចន្លោះខ្វះខាតដែលពាក់ព័ន្ធនឹងការ ប្រាស្រ័យទាក់ទងអន្តរវប្បធម៌ ។



# ដំណើររឿងជោគជ័យពីអ្នកស្ម័គ្រចិត្ត

## ក្លឹបភាសាអង់គ្លេសក្នុងអំឡុងពេលវិសមកាល ពីអ្នកស្ម័គ្រចិត្ត ភីស ខ័រ Catherine Cramer នៅខេត្តតាកែវ




នៅចុងឆ្នាំសិក្សា នាយកសាលាខ្ញុំនិងគ្រូដៃគូ បានមកពិភាក្សាជាមួយខ្ញុំអំពីគំនិតបង្កើតក្លឹបភាសាអង់គ្លេសមួយ។ កម្មវិធីនេះ នឹងដំណើរការក្នុងអំឡុងពេលវិសមកាលហើយផ្តោតលើសិស្សវិទ្យាល័យ។ ខ្ញុំមានក្តីរំភើបចំពោះឱកាសធ្វើការជាមួយ សហគមន៍បន្ថែមទៀត ប៉ុន្តែ ក៏មានការព្រួយបារម្ភបន្តិចផងដែរ។ បទពិសោធន៍របស់ខ្ញុំភាគច្រើនធ្វើការជាមួយសិស្សបឋមសិក្សា ហើយលើកចុងក្រោយដែលខ្ញុំបានបង្រៀនសិស្សដែលមានវ័យច្រើនជាងនេះគឺក្នុងអំឡុងពេលអនុវត្តវគ្គបណ្តុះបណ្តាលបឋម។ ទោះជាយ៉ាងណា ខ្ញុំបានទទួលយកការប្រឈមនេះ ហើយចាប់ផ្តើមធ្វើការភ្លាមៗ។

គ្រូដៃគូរបស់ខ្ញុំបានជួយផ្សព្វផ្សាយក្លឹបនេះនៅសាលាឯកជនដែលគាត់បង្រៀន ហើយខ្ញុំបានបង្កើតព័ត៌មានរូបភាព (infographic) ដើម្បីចែករំលែកនៅលើបណ្តាញសង្គមហ្វេសប៊ុក។ ការផ្សព្វផ្សាយព័ត៌មានគឺមានសារៈសំខាន់ណាស់ដើម្បីទាក់ទាញដល់សិស្សដែលមានចំណាប់ចំណូលចិត្តពីសហគមន៍ ហើយខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងរីករាយចំពោះការឆ្លើយតបដែលទទួលបាន។

ថ្ងៃដំបូង គឺសម្រាប់ការចុះឈ្មោះនិងការណែនាំទិសដៅ។ ខ្ញុំចង់ដឹងថាតើមានសិស្សប៉ុន្មាននាក់ដែលចាប់អារម្មណ៍ និងថាតើក្រុមអាយុណាដែលខ្ញុំនឹងធ្វើការជាមួយជាចម្បង។ ជាការភ្ញាក់ផ្អើល អ្នកចូលរួមប្រហែល ៣០នាក់បានបង្ហាញខ្លួន ភាគច្រើនជាសិស្សថ្នាក់ទី១០ និងគ្រូបង្រៀនក្នុងមូលដ្ឋានមួយចំនួនផងដែរ។

ពេលខ្ញុំសួរថាតើពួកគេចង់ផ្តោតលើអ្វី ចម្លើយដ៏លើសលុបគឺ “ការហាត់និយាយ”។ ដោយឆ្លុះបញ្ចាំងពីបញ្ហាប្រឈមទូទៅដែលខ្ញុំបានកត់សម្គាល់ឃើញនៅក្នុងការសន្ទនាពីមុន ខ្ញុំបានសម្រេចចិត្តផ្តោតក្លឹបនេះលើការកសាងទំនុកចិត្តក្នុងការនិយាយ និងការអភិវឌ្ឍការសន្ទនាឱ្យមានភាពស្ទាត់ជំនាញ ។

យើងបានជួបគ្នា ៣ដង ក្នុងមួយសប្តាហ៍ម្តងៗរយៈពេលពីរម៉ោង។ម៉ោងដំបូងមានរចនាសម្ព័ន្ធច្បាស់លាស់ដោយផ្តោតលើការណែនាំវាក្យសព្ទ ការបញ្ចេញសំឡេង និងឧទាហរណ៍នៃការសន្ទនា។ជាញឹកញាប់ ខ្ញុំបានធ្វើគំរូនៃការសន្ទនា សម្តែងរឿងកំប្លែង ឬពន្យល់បរិបទវប្បធម៌នៃឃ្លាភាសាអង់គ្លេសមួយចំនួន។ ម៉ោងទីពីរ គឺជាពេលដែលថាមពលមានលក្ខណៈរស់រវើក។ យើងបានចំណាយពេលនោះហាត់និយាយតាមរយៈការលេងល្បែងសិក្សា ការពិភាក្សាជាក្រុម និងការសម្តែងតួ។ ខ្ញុំបានណែនាំល្បែងភាសាមួយចំនួនដែលខ្ញុំចូលចិត្តដែលជំរុញទឹកចិត្តឱ្យមានចលនា និងភាពច្នៃប្រឌិត ហើយសិស្សក៏បានបង្រៀនខ្ញុំពីល្បែងដែលពួកគេធ្លាប់លេងតាំងពីកុមារភាពផងដែរ ដោយយើងបានកែសម្រួលវាទៅជាសកម្មភាពនិយាយភាសាអង់គ្លេស។

ការបង្រៀនសិស្សធំៗ ទាមទារឱ្យខ្ញុំផ្លាស់ប្តូរវិធីសាស្ត្របង្រៀន។ ខ្ញុំបានដឹងយ៉ាងឆាប់ថា របៀបបង្រៀន ដែលមានលក្ខណៈសកម្មខ្លាំង និងរស់រវើកដែលខ្ញុំប្រើសម្រាប់សិស្សថ្នាក់តូចៗ ត្រូវការការកែសម្រួលខ្លះ។ ថ្វីបើសិស្សបឋមសិក្សាឆ្លុះបញ្ចាំងពីភាពរីករាយរបស់ខ្ញុំក្តី ក៏សិស្សវិទ្យាល័យនៅពេលដំបូងហាក់ដូចជាភ័យខ្លាចចំពោះភាពរីករាយនេះដែរ។ ខ្ញុំត្រូវស្វែងរកនូវតុល្យភាពរវាងការចូលរួម និងការរក្សាភាពស្ងប់ស្ងាត់សមរម្យ។ តាមរយៈការសាកល្បងមួយចំនួន សំណើច និងការឆ្លុះបញ្ចាំងខ្លួនឯង ខ្ញុំបានរកឃើញចង្វាក់របស់ខ្ញុំ និងបានរៀនសូត្រយ៉ាងច្រើនអំពីភាពសុភាពរាបសារ និងភាពបត់បែន។






ក្នុងរយៈពេលមួយខែនេះ ខ្ញុំបានឃើញសិស្សរបស់ខ្ញុំប្រែក្លាយពីអ្នកនិយាយដែលខ្មាស់អៀន និងស្ទាក់ស្ទើរ ទៅជាអ្នកប្រាស្រ័យទាក់ទងប្រកបដោយទំនុកចិត្ត និងបង្ហាញអារម្មណ៍កាន់តែច្បាស់ជាងមុន។ ការមើលឃើញពួកគេហ៊ានប្រើភាសាអង់គ្លេស និងគាំទ្រគ្នាទៅវិញទៅមក បានរំលឹកខ្ញុំអំពីមូលហេតុដែលខ្ញុំចូលចិត្តបង្រៀន។ វាមិនមែនគ្រាន់តែអំពីភាសាប៉ុណ្ណោះទេ ប៉ុន្តែ អំពីការផ្សារភ្ជាប់ ការរីកចម្រើន និងភាពក្លាហានរួមគ្នា។

## រៀនពីវិធីថ្មីៗក្នុងការថែទាំគ្រួសារនៅកម្ពុជា ពីអ្នកស្ម័គ្រចិត្ត ភីស ខ័រ Caleb Williams នៅខេត្តព្រៃវែង



សមាហរណកម្មវប្បធម៌ត្រូវបានរំលេចនៅក្នុងគោលដៅទីពីររបស់ទីភ្នាក់ងារ ភីស ខ័រ ពោលគឺ "សំដៅជួយលើកកម្ពស់ការយល់ដឹងកាន់តែប្រសើរឡើងអំពីប្រជាជនផ្សេងទៀតដោយជនជាតិអាមេរិក" ប៉ុន្តែ រហូតដល់ពេលដែលខ្ញុំបានរស់នៅជាមួយគ្រួសារខ្មែរខ្ញុំ ទើបខ្ញុំចាប់ផ្តើមយល់ថាសមាសភាគនេះអាចមានឥទ្ធិពលលើជីវិតខ្ញុំយ៉ាងជ្រាលជ្រៅប៉ុណ្ណា។ក្រោយពីបានរស់នៅជាមួយគ្រួសារខ្មែរក្នុងភូមិអស់រយៈពេលពីរបីខែ (គ្រប់គ្រាន់ដើម្បីមានអារម្មណ៍ថាបានធ្វើសមាហរណកម្មយ៉ាងពេញលេញទៅក្នុងវប្បធម៌គ្រួសារ) ខ្ញុំគិតថា ខ្ញុំបានយល់ពីវប្បធម៌គ្រួសារនៃគ្រួសារខ្មែរខ្ញុំ ប៉ុន្តែ ពួកគេនៅតែអាចធ្វើឱ្យខ្ញុំភ្ញាក់ផ្អើលតាមរយៈរបៀបដែលពួកគេបង្ហាញការថែរក្សានិងការយកចិត្តទុកដាក់។

បន្ទាប់ពីជួបបញ្ហារអាក់រអួលខ្លះជាមួយក្រុមគ្រួសារនៅសហរដ្ឋអាមេរិក និងឆ្លងកាត់បទពិសោធន៍មិនល្អខ្លះៗ ជាមួយមនុស្សនៅក្នុងសហគមន៍ ខ្ញុំមានអារម្មណ៍ថាអស់កម្លាំង និងគ្មានការលើកទឹកចិត្ត ដែលបណ្តាលឱ្យខ្ញុំដកខ្លួនចេញពីអ្នកដទៃ។ គ្រួសារខ្ញុំបានសង្កេតឃើញ ហើយនៅពេលដែលពួកគេសួរខ្ញុំថាតើមានរឿងអ្វីកើតឡើង ខ្ញុំបានប្រាប់ពួកគេដោយស្ទាក់ស្ទើរថា ខ្ញុំមិនចេះពាក្យខ្មែរគ្រប់គ្រាន់ដើម្បីពន្យល់ពីបញ្ហាដែលគ្រួសារអាមេរិកខ្ញុំកំពុងជួបប្រទះនោះទេ។ ប៉ុន្តែ ខ្ញុំបានពន្យល់ពីបទពិសោធន៍មិនល្អនៅក្នុងភូមិ ដែលងាយស្រួលពន្យល់ និងមិនសូវមានលក្ខណៈឯកជន។ ពួកគេបានមកគាំទ្រខ្ញុំភ្លាមៗ លើកទឹកចិត្តខ្ញុំ និងជួយខ្ញុំស្វែងរកដំណោះស្រាយ។ ជាពិសេស មីងខ្ញុំបានដឹកនាំ និងបង្រៀនខ្ញុំអំពីទម្លាប់វប្បធម៌ដែលគាត់អនុវត្តនៅពេលដែលគាត់មានទុក្ខព្រួយ។ គាត់បានប្រាប់ខ្ញុំថាគាត់ទៅវត្ត ហើយសូមឱ្យព្រះសង្ឃស្រោចទឹក។ គាត់ក៏បានណែនាំខ្ញុំឱ្យពាក់ "ខ្សែកថាចង្កះ" ដើម្បីការពារបទពិសោធន៍អវិជ្ជមានជាមួយអ្នកដទៃនៅជុំវិញ និងដើម្បីសំណាងល្អក្នុងអាជីពរបស់ខ្ញុំផង។ បន្ទាប់ពីខ្ញុំបានយល់ព្រមតាមសំណើរបស់គាត់ គាត់បាននាំខ្ញុំទៅវត្តដើម្បីធ្វើពិធីស្រោចទឹក ហើយរៀបចំប្រាក់ដើម្បីប្រគេនព្រះសង្ឃសម្រាប់ខ្សែកថា ដែលខ្ញុំនៅពាក់រហូតមកដល់សព្វថ្ងៃនេះ។

បទពិសោធន៍ទាំងនេះបានបង្រៀនខ្ញុំថា ទោះបីជាក្រុមគ្រួសារខ្មែរខ្ញុំមិនយល់ច្បាស់ពីបញ្ហាទាំងអស់ដែលខ្ញុំកំពុងជួបក៏ដោយ ពួកគេយល់ពីអារម្មណ៍ខ្ញុំ ហើយបានប្រើវិធីសាស្ត្រដែលពួកគេមានដើម្បីមើលថែខ្ញុំ ទោះបីជាខ្ញុំមិនយល់ច្បាស់ពីពួកគេដោយសារសាវតារវប្បធម៌មានកម្រិតរបស់ខ្ញុំក៏ដោយ។ថ្វីបើយើងមិនយល់ពេញលេញអំពីបញ្ហានិងទម្លាប់អនុវត្តរវាងគ្នាក៏ដោយ ក៏យើងបានយល់ពីសេចក្តីស្រឡាញ់ និងចេតនាល្អនៅពីក្រោយសកម្មភាពទាំងនោះ ហើយនៅពេលដែលខ្ញុំបានអនុញ្ញាតឱ្យខ្លួនឯងទុកចិត្តលើគ្រួសារខ្មែរជាមួយបញ្ហាដែលខ្ញុំកំពុងប្រឈមមុខ ការយកចិត្តទុកដាក់ របស់ពួកគេចំពោះខ្ញុំបានផ្តល់នូវថាមពលនិងភាពធន់ជាថ្មី ដែលជួយឱ្យខ្ញុំអាចបន្តឆ្លងកាត់ការលំបាករហូតដល់ចុងបញ្ចប់នៃការងាររបស់ខ្ញុំ និងលើសពីនេះទៅទៀត។








These are the smiling faces of Peace Corps Cambodia! #Smile
#PeaceCorps #Cambodia #Volunteer #ApplyToday #ServeBoldly
500 comments
1k shares



Peace Corps
CAMBODIA




















































# ការឆ្លុះបញ្ចាំងអំពីបទពិសោធន៍នៅប្រទេសកម្ពុជា

ផាសុខភាព ភាពរឹងមាំ សេចក្តីស្រឡាញ់ ភាពវិជ្ជមាន ស្នាមញញឹម សហគមន៍

ការស្វប់ស្វែង ថាមពល អនុស្សាវរីយ៍ ភាពអត់ធ្មត់ គ្រួសារ ផ្ទះ...









**ទីស្នាក់ការ ពីស ខ័រ កម្ពុជា**

ផ្ទះលេខ ៧អា ផ្លូវលេខ ២៥៦

រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ២៤៥៣

ទូរស័ព្ទលេខ៖ (៨៥៥) ២៣ ២២២ ៩០១

ទូរសារលេខ៖ (៨៥៥) ២៣ ២២២ ៩០៣

អ៊ីម៉ែល៖ KH-WebInfo@peacecorps.gov

**Follow us:**